**BMI0067**

សម្ភាសជាមួយឈ្មោះ សោម យ៉េង ភេទ ប្រុស

អាយុ៧៣ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ យោធាតំបន់

មុខងារបច្ចុប្បន្នៈ "ធ្វើស្រែ ធ្វើចំការ"

មានស្រុកកំណើតនៅៈ ភូមិពោធិ៍ទន្លេ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល

សព្វថ្ងៃរស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី២០ខែ តុលា ឆ្នាំ ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០២:០៥:២៥

សរុបៈ៤៥ទំព័រ

ដានី ៖ ជំរាបសួរ ខ្ញុំសុំស្គាល់ឈ្មោះអ៊ំៗ ឈ្មោះអីដែរ?

យ៉េង ៖ ខ្ញុំឈ្មោះគឺ សោម យ៉េង

ដានី ៖ អ៊ំអត់មានឈ្មោះប្រែអីទេ?

យ៉េង ៖ អត់មានប្រែអីទេ តាំងពីកំណើតកើតជាមកគឺឈ្មោះ សោម យ៉េង ហ្នឹង

ដានី ៖ ចុះអ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

យ៉េង ៖ ខ្ញុំអាយុ៧៣ឆ្នាំ

ដានី ៖ សព្វថ្ងៃអ៊ំក្នុងភូមិនេះគេហៅភូមិអីទៅអ៊ំ?

យ៉េង ៖ ភូមិសង្កែ ឃុំបឹងប៉េង ស្រុកម៉ាឡៃ

ដានី ៖ ចុះគ្រួសារអ៊ំគាត់ឈ្មោះអីទៅ?

យ៉េង ៖ យ៉េប ម៉េង

ដានី ៖ គាត់អាយុប៉ុន្មានដែរសព្វថ្ងៃ?

យ៉េង ៖ អាយុ ៦៨ ហើយ

ដានី ៖ បាទ! អ៊ំសព្វថ្ងៃប្រកបរបបរកស៊ីអីដែរ?

យ៉េង ៖ ខ្ញុំធ្វើស្រែចំការ

ដានី ៖ អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

យ៉េង ៖ កូនវាបើនិយាយពីជីវិតរស់នៅមានតែ៣នាក់ទេ

ដានី ៖ អញ្ចឹងអ៊ំមានកូនគាត់បាត់បង់ជីវិត?

យ៉េង ៖ បាត់បង់ជីវិតហ្នឹងអត់មានបាត់បង់នៅភូមិសង្គ្រាមទេ បាត់បង់ដោយគេហៅថាជំងឺរោគ គារខ្លួនឯងផ្ទាល់ មិនមែនបាត់បង់ក្នុងសង្គ្រាមទេ។

ដានី ៖ គាត់បាត់បង់ទៅអស់ប៉ុន្មាននាក់ទៅ?

យ៉េង ៖ អស់៧នាក់

ដានី ៖ អស់៧នាក់?

យ៉េង ៖ បាទ!

ដានី ៖ អស់៧នាក់ អ៊ូ!ច្រើន អញ្ចឹង៧នាក់ហ្នឹងសុទ្ធតែជំងឺ?

យ៉េង ៖ បាទ!កើតជំងឺ

ដានី ៖ ជំងឺនៅណាទៅ?

យ៉េង ៖ បាទ!ជំងឺនៅស្រុក

ដានី ៖ ចុះ៣នាក់ហ្នឹងសព្វថ្ងៃគាត់រស់នៅណា?

យ៉េង ៖ នៅនេះ២ នៅធ្វើដូវនៅ សៀមរាប១នាក់

ដានី ៖ ៣នាក់ហ្នឹងស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យ៉េង ៖ ប្រុសទាំង៣

ដានី ៖ ចុះអ៊ំស្រុកកំណើតអ៊ំនៅណាទៅ?

យ៉េង ៖ នៅកោះធំ

ដានី ៖ កោះធំហ្នឹងភូមិអី ឃុំអីទៅ?

យ៉េង ៖ នៅភូមិពោធិ៍ទន្លេ ឃុំកោះធំ ស្រុកកោះធំកណ្ដាល ខេត្តកណ្ដាល

ដានី ៖ ចុះអ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ នៅកោះធំ បងប្អូនបង្កើត?

យ៉េង ៖ បងប្អូនបង្កើតគឺថាអានេះខ្ញុំនិយាយពីពោះខ្ញុំបង្កើតមាន៥ នាក់

ដានី ៖ ៥នាក់ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យ៉េង ៖ ស្រី២នាក់ ប្រុស៣នាក់

ដានី ៖ ចុះអ៊ំកូនទីប៉ុន្មាន?

យ៉េង ៖ ខ្ញុំកូនទី៤

ដានី ៖ ឪពុកម្ដាយអ៊ំគាត់អើ?

យ៉េង ៖ អនិច្ចកម្មបាត់

ដានី ៖ គាត់ខូចតាំងពីអន្កាល់?

យ៉េង ៖ បើម្តាយខ្ញុំគាត់អនិច្ចកម្មតាំងពីខ្ញុំអាយុ១០ឆ្នាំ

ដានី ៖ ចុះឪពុក?

យ៉េង ៖ ឪពុកគាត់ទឹមអនិច្ចឆ្នាំ៨៦

ដានី ៖ អ្ហូ!អញ្ជឹង

យ៉េង ៖ បាទ!ខ្ញុំនៅនេះ

ដានី ៖ ម្តាយអ៊ំឈ្មោះអីទៅ?

យ៉េង ៖ ម្តាយឈ្មោះ ពេជ្រ ការ

ដានី ៖ ឪពុក?

យ៉េង ៖ ឪពុក សោម ទឹម

ដានី ៖ ចុះអ៊ំកាលពីនៅស្រុកកំណើតអ៊ំធ្វើអីដែរ?

យ៉េង ៖ បាទ!កាលដែលនៅពីក្មេងខ្ញុំប្រកបអាជីវកម្មធ្វើចំការ ស្រុកខ្ញុំគេហៅថាធ្វើស្រូវពង្រោះ ធ្វើចំការដាំពោត ដាំសណ្តែក ។

ដានី ៖ ចុះអ៊ំកាលពីក្មេងៗអ៊ំរៀនសូត្រដល់ណាដែរ?

យ៉េង ៖ រៀនសូត្រៗដល់កំរិតវប្បធម៌ គ្រាន់តែវាខ្សោយ បើយើងនិយាយទៅវាក្នុងលក្ខណៈថ្នាក់អក្ខរកម្ម អាចអានបាន សរសេរវាមិនបានត្រឹមត្រូវតាមព្យញ្ជនៈ ។

ដានី ៖ ចុះអ៊ំរៀបការជាមួយអ៊ំស្រីតាំងពីឆ្នាំណា?

យ៉េង ៖ តាំងពីអាយុ២១ឆ្នាំ

ដានី ៖ តាំងពីជំនាន់ណាហ្នឹង?

យ៉េង ៖ តាំងពីជំនាន់សម្តេច

ដានី ៖ បាទ!ចុះអ៊ំរៀបការហើយអ៊ំធ្វើអីទៅ?

យ៉េង ៖ ធ្វើស្រែចំការ

ដានី ៖ ធ្វើស្រែចំការនៅភូមិកំណើតហ្នឹង?

យ៉េង ៖ បាទ!ធ្វើនៅភូមិកំណើតហ្នឹងប៉ុន្តែ ក្រោយម៉ោខ្ញុំទៅនៅខេត្តព្រៃវែង ស្រុកពាមជ័ ក៏ទៅធ្វើចំការដែរ ។

ដានី ៖ ទៅនៅហ្នឹងនៅស្រុកកំណើតខាងអ៊ំស្រីឬក៏យ៉ាងម៉េច?

យ៉េង ៖ អត់អ៊ើ្រស្រីក៏គាត់កំណើតកើតជានៅស្រុក ភូមិ ឃុំជាមួយគ្នាដែរ ។

ដានី ៖ បាទៗ!អញ្ចឹងទៅស្រែចំការនោះ?

យ៉េង ៖ ទៅធ្វើចំការនោះវាកាលពីដើម ក៏មានបងប្អូនកាលនោះកាលជំនាន់សម្តេច ដីនោះគេហៅថាដីយួនវានៅនេះ១ដុំ នៅនោះ១ដុំ ដល់អញ្ចឹងទៅបងប្អូនទៅបានដីដែលនៅសល់ទំនេរហ្នឹង ដល់វានបានទៅឆ្នាំ៦៩ខ្ញុំទៅនៅជាមួយបងប្អូន គេឲ្យទៅនៅធ្វើចំការ ដាំថ្នាំនៅជាមួយបងប្អូននៅហ្នឹង ដល់ឆ្នាំ៧០រដ្ឋប្រហារនេះខ្ញុំម៉ោនៅស្រុកវិញ ។

ដានី ៖ ធ្វើអីទៀតទៅដីរដ្ឋប្រហារឆ្នាំ៧០?

យ៉េង ៖ ដល់ក្រោយម៉ោឆ្នាំ៧០រដ្ឋប្រហារហ្នឹងគឺថាវាមាន ដូចថានិន្នាការនយោបាយ និន្នាការនយោបាយហ្នឹងគឺ វាមានកាលពីជំនាន់នោះគេហៅថាគឺទាំងចាស់ទាំងក្មេងគឺតែងតែគោរពស្តេច អញ្ចឹងធ្វើរដ្ឋប្រហារស្តេច ទាមទារដើម្បីសុំឲ្យស្តេចចូលមកស្រុកវិញ ដល់អញ្ចឹងធ្វើនយោបាយហ្នឹងក៏យើងជឿតាមនយោបាយហ្នឹងទៅ មិនដឹងថាគេធ្វើរបៀបម៉េចៗខ្ញុំអត់ដឹងទេ ដឹងតែពីថាយើងគឺថាគាំទ្រស្តេច ដល់គាំទ្រស្តេចទៅយើងចូលតស៊ូនៅក្នុងព្រៃទៅ ឆ្នាំ៧០ ខែ៥ថ្ងៃទី៥ខ្ញុំចេញចូលតស៊ូ ។

ដានី ៖ កាលហ្នឹងសម្តេចគាត់ព្រះអង្គគាត់ពំពាវនាវមកពីក្រៅម៉ោ ឲ្យយើងមកចូលព្រៃម៉ាក់គីតស៊ូ?

យ៉េង ៖ បាទៗ!ថានោះអឺខៀវ សំផន នីងពូនីម ពូយ៉ុន គាត់ថាគាត់បើសម្លាប់អ្នកទាំង៣នាក់ ហ្នឹងប្រៀបបានដូចជាសម្លាប់ព្រះអញ្ចឹង បើសម្លាប់១គឺកើត១០កើត១០០ឬ១០០០នាក់អញ្ចឹង កាលហ្នឹងសម្តេងសម្តេចគាត់ស្រែថាឲ្យអ្នកទាំង៣នាក់ហ្នឹងភៀសខ្លួនចេញទៅព្រៃម៉ាក់គីនោះ ។

ដានី ៖ អញ្ចឹងអឺកាលហ្នឹងអឺចូលតស៊ូចូលពីខាងណាទៅ?

យ៉េង ៖ បាទ!នៅក្នុងស្រុកកោះអធំនោះកាលហ្នឹងវាមានក្នុងលក្ខណៈហ្នឹងវាមានពីដើមវាមានរដ្ឋអំណាចយួនៗហ្នឹងគឺថាទី១ យួននៅភាគខាងជើង

ដានី ៖ បាទៗ!

យ៉េង ៖ កាលពីជំនាន់អ៊ីសារ៉ាក់មានខ្មែរយើងមួយចំនួនគឺ ដល់ពេលអ៊ីសារ៉ាក់យើងចាប់ទៅក៏ទៅយួនភាគខាងជើង ដល់ពេលហ្នឹងយួនភាគខាងជើងម៉ោមានទាំងខ្មែរមកជាមួយ ចលនាហ្នឹងយើងឃើញមានខ្មែរមានអីយើងហៅថាចលនាទាមទារសម្តេច ប៉ុន្តែក្នុងន័យរបស់គេយើងអត់ដឹងទេ ព្រោះយើងយល់ថាសម្តេចធ្លាប់គាត់គ្រប់គ្រងប្រទេសជាតិ ឃើញថាប្រជាជនទូទាំងប្រទេសគាំទ្រហើយ អញ្ចឹងយើងជឿហើយទាមទារសម្តេចមកវិញ អា

ហ្នឹងមានប៉ុណ្ណឹង ។

ដានី ៖ បាទៗ!កាលជំនាន់អ៊ីចូលព្រៃកាលហ្នឹងមានខាងយួនខាងជើងក៏ម៉ោដែរ?

យ៉េង ៖ បាទ!មាន

ដានី ៖ យួនខាងជើង ខ្មែរខាងជើងក៏ម៉ោដែរ?

យ៉េង ៖ បាទ!ម៉ោជាមួយគ្នា

ដានី ៖ កាលហ្នឹងពួកណាខ្លះអ៊ីមានចាំឈ្មោះពួកគាត់ដែរឬអត់?

យ៉េង ៖ ខ្មែរយើងដែលទៅខាងជើងឥឡូវគាត់ស្លាប់អស់ហើយ ។

ដានី ៖ បាទ!ប៉ុនគាត់ឈ្មោះអីខ្លះទៅ?

យ៉េង ៖ ប៉ុន្តែអត់ស្គាល់នាមត្រកូលទេណា!

ដានី ៖ បាទៗ!

យ៉េង ៖ ឈ្មោះ ហម ឈ្មោះ ហមមួយ មួយនោះគាត់ឆែបមាត់ហៅគាត់តែតាឆែបៗអាហ្នឹងខ្មែរយើងជាមួយយួនខាងជើង ឈ្មោះ ហមនោះស្ថិតក្នុងនៅក្នុងស្រុកកោះធំ ឈ្មោះ ឆែបនោះនៅក្នុងស្រុកលើកដែក ឈ្មោះ ហ៊ុយ នៅក្នុងស្រុកកោះធំដែរ ប៉ុន្តែឃុំពង់ កុងបាទ!៣នាក់ហ្នឹងគឺថាខ្ញុំ ។

ដានី ៖ បាទ!ហើយចុះកាលជំនាន់តស៊ូហ្នឹងគឺថាខាងតស៊ូ កាលហ្នឹងមន្ទីរគេនៅណាទៅ?

យ៉េង ៖ បាទ!មន្ទីរវាមានច្រើនកន្លែង

ដានី ៖ មន្ទីរតំបន់២៥?

យ៉េង ៖ បាទ!មន្ទីរតមបន់២៥ហ្នឹងវាមានច្រើនកន្លែង គឺថាកន្លែងខាងអប់រំហ្នឹងគេធ្វើមន្ទីរគេ១ ទៅអាកន្លែងមន្ទីរស្នាក់នៅរបស់គណៈតំបន់ហ្នឹងនៅផ្សេងទៅ កន្លែងមន្ទីរកន្លែងរោងពុម្ពសម្រាប់អូសឯកសារអីនៅផ្សេងទៅ មន្ទីរខាងជួសជុលប្រដាប់អាវុធនៅផ្សេងទៅវាដោយឡែកពីគ្នា ។

ដានី ៖ បាទ!កាលហ្នឹងកន្លែងអ៊ីទៀវ សំដន នឹងអ៊ី ហូរ នឹម គាត់នៅកន្លែងណាទៅ?

យ៉េង ៖ កាលហ្នឹងខ្ញុំអត់មានដឹងកន្លែងគាត់ទេ គ្រាន់តែថាខ្ញុំវាក្មេងឆ្នាំ ក្មេងឆ្នាំទៅក្រោយម៉ោប្រជុំសន្តិបាតនៅស្រុកកោះធំ សាលាស្រុកកោះធំ ដល់ហើយម៉ោវាមានបញ្ហាអីក៏គេ នាំហូរ នឹម ចេញម៉ោខាងខេត្តតាកែវម៉ោ បាត់តាំងពីហ្នឹងម៉ោរហូត មិនដឹងជាគាត់ទៅណាអីណាកាលហ្នឹង ។

ដានី ៖ អញ្ចឹងឆ្នាំ៧០ហ្នឹងនៅសាលាស្រុកកោះធំខាងកងរំដោះយើងគ្រប់គ្រង?

យ៉េង ៈ ឆ្នាំ៧០ហ្នឹងវា ព្រោះកាលរៀនសាលានៅស្រុកកោះធំមិនដឹងជាឆ្នាំប៉ុន្មានទេខ្ញុំក៏ភ្លេចដែរ មិនមែនឆ្នាំ៧០ទេ ដែលមានខ្មែរក្រហមនៅគ្រប់គ្រងដូចមិនមែនឆ្នាំហ្នឹងទេ ខ្ញុំនិយាយនេះគឺថាដល់យើងរំដោះទីតាំងនេះបានហើយ បានខ្ញុំទៅប្រជុំសន្និបាតនៅកន្លែងហ្នឹង ហ្នឹងក្រោយមមកមុនរំដោះភ្នំពេញ បើរំដោះភ្នំពេញឆ្នាំ៧៥ ប៉ុនគ្រាន់តែខ្ញុំអត់ចាំថ្ងៃខ្ញុំហើយបាត់អាំហ្នឹងរហូតទៅ ។

ដានី ៈ បាទ!ចុះខាងគណៈតំបន់២៥ កាលហ្នឹងឈ្មោះអីខ្លះទៅ?

យ៉េង ៈ គណៈតំបន់កាលពីមុនយួនគ្រប់គ្រង ឈ្មោះ តាបាវ ខ្មែរភាគខាងជើងដែរ គាត់នៅប៉ុននៅកំពង់គរ ។

ដានី ៈ ចុះខាងខ្មែរយើង?

យ៉េង ៈ អាហ្នឹងកាលហ្នឹងគឺយួនគ្រប់គ្រង ប៉ុនកាលហ្នឹងក្រោយម៉ោមានព្រឹត្តិការណ៍ខ្មែរនឹងយួនមានព្រឹត្តិការណ៍ទំនាស់គ្នា ។

ដានី ៈ ឆ្នាំណាហ្នឹង?

យ៉េង ៈ អត់ចាំឆ្នាំទេ ខ្ញុំអត់បានទៅគិតគូរអីពីរឿងអាបញ្ហាហ្នឹង កាលហ្នឹងខ្ញុំនៅក្នុងយោធាហ្នឹងដែរ ។

ដានី ៈ អាំនៅយោធាតំបន់?

យ៉េង ៈ បាទ!យោធាតំបន់នោះដែរ ដ៏ឈ្មោះគ្នាហ្នឹងគឺរវៃខ្មែរនឹងខ្មែរ ខ្មែរហើយនឹងយួនប្រទូសប្រទ្រាស់គ្នាមួយសារទៀត ព្រោះកាលហ្នឹងក៏ខ្ញុំនៅក្នុងតំបន់នឹងក៏ប៉ុន្តែយួនគ្រប់គ្រង ប៉ុនទៅមានខ្មែរមួយផ្នែក ដល់អញ្ចឹងខ្ញុំក៏គេឲ្យខ្ញុំមកនៅខាងតាកែវ ដល់អញ្ចឹងយួនវា មកធ្វើនយោបាយថាឥឡូវហ្នឹងមិត្តយើងគឺ ត្រូវអន្តការខ្មែរយើងគឺថាឲ្យខ្មែរយើងវិញ ត្រឡប់ទៅវិញ ក៏ប៉ុន្តែអាវុធគឺថាអត់ឲ្យយកទៅវិញទេ គឺអាវុធទុកនៅហ្នឹងគឺថាយើងទៅទទួលអាវុធថ្មី ។

ដានី ៈ បាទៗ!

យ៉េង ៈ ដល់ខ្ញុំម៉ោគឺចាញ់បោកយួន យួនប្រមូលយកអាវុធអស់ ។

ដានី ៈ ឆ្នាំណាអាំ?

យ៉េង ៈ វាអើបើមិន៧១ វាប្រហែលជា៧១ហ្នឹង ៧២ខ្ញុំម៉ោនៅតំបន់វិញហើយ ម៉ោនៅខាងខ្មែរវិញហើយ ។

ដានី ៈ ខាងយោធាហ្នឹងអាំមានតួនាទីជាអ្នកទទួលខុសត្រូវដែរ?

យ៉េង ៖ អត់មានទេ

ដានី ៖ ពីណាគេកាលហ្នឹង?

យ៉េង ៖ យួនគេគ្រប់គ្រង ខ្មែរមានត្រឹមធំបំផុតត្រឹមប្រធានក្រុម ។

ដានី ៖ ដល់ពេលឆ្នាំ៧២ខ្មែរយើងគ្រប់គ្រងវិញ?

យ៉េង ៖ បាទ!អាហ្នឹងខ្ញុំ មានកន្លែងខ្មែរគ្រប់គ្រង

ដានី ៖ ពីណាគេកាលហ្នឹង?

យ៉េង ៖ អាហ្នឹងក្រោយម៉ោ ប្រទូសប្រទ្រាស់គ្នាហើយ មានតា នង សួន អ្នកខ្លះហៅជ័យ ហ្នឹងក្រោយម៉ោគាត់គ្រប់គ្រងរហូតទល់គ្នាម៉ោយើងជិតាស់ ។

ដានី ៖ ពីណាខ្លះក្នុងក្រុមរបស់គាត់?

យ៉េង ៖ ខ្ញុំចាំមិនអស់ទេ!មានតាហួតសេ តាហួតសេហ្នឹងបើតាមនេះទៅគាត់ខ្សែរបស់ស្តេច តាហួយសេ តាអេស៊ាក្លេចបាត់ហើយ ។

ដានី ៖ ចុះតាសុខប៉ុតចំរើន?

យ៉េង ៖ ហ្នឹងហើយតាសុខប៉ុតចំរើន ក្នុងអចិន្ត្រៃយ៍របស់គាត់ ឥឡូវខ្ញុំនិយាយអត់លាក់ទេ វាមានបងជីដូនមួយខ្ញុំមួយទៀត មេបញ្ជាការទ័ពតំបន់ ។

ដានី ៖ បាទ!គាត់ឈ្មោះអី?

យ៉េង ៖ ឈ្មោះ តាសុខ

ដានី ៖ អូ្ហ!តាសុខហ្នឹង?

យ៉េង ៖ បាទ!

ដានី ៖ ហ្នឹងបងជីដូនមួយអ៊ំ?

យ៉េង ៖ បាទ!

ដានី ៖ គាត់មេបញ្ជាការតំបន់២៥ហ្នឹង?

យ៉េង ៖ បាទ!

ដានី ៖ ចុះអ៊ំកាលហ្នឹងអ៊ំម៉ោធ្វើអីវិញកាលហ្នឹង?

យ៉េង ៖ ខ្ញុំនៅនិរសា

ដានី ៖ និរសារបស់គាត់?

យ៉េង ៖ គាត់និរសារបស់គាត់ទេ!នៅមន្ទីរតំបន់ហ្នឹង ព្រោះគាត់ខាងយោធា ខ្ញុំខាងចេះខ្ញុំជំរាបឲ្យត្រង់ខ្ញុំអត់លាក់ទេអារឿងបញ្ហាហ្នឹង វាផុតពីសេចក្តីស្លាប់ហើយខ្ញុំ ព្រោះខ្ញុំធ្វើមិន

ដែលធ្វើឲ្យអ្នកណាមានទុកទោសផលរមាស់អារឿងខ្ញុំទេ ។

ដានី ៖ បាទៗ!

យ៉េង ៖ និរសាហ្នឹងគឺនិរសាថាឥឡូវត្រូវឡើងម៉ោភូមិភាគ ម៉ោអមលាំងត្រពាំងដោរនេះមានគ្នាប៉ុន្មាន ៥០នាក់អញ្ចឹងទៅកត់ទៅ ហើយអាវុធគ្រប់ដៃឡើងម៉ោឆ្លងកាត់ឱរ៉ាល ម៉ោខាងលិចត្រពាំងក្រឡឹងជញ្ជូនផរ៉ាន់ម៉ោ ដឹកកាំភ្លើងយកចុះទៅវិញ ។

ដានី ៖ កាលហ្នឹងអ៊ើ!កាលអ៊ំទៅនិរសាទៅខាងអមលាំងមានដែលជួបពូ ចៀម?

យ៉េង ៖ ចៀមយើងនេះ?

ដានី ៖ បាទ!

យ៉េង ៖ អត់ទេ!បើគាត់ឡង់មួយនោះ គាត់ធ្លាប់នៅជាមួយពូ ចៀម គាត់ធ្លាប់នៅជាមួយទាំង អស់ហើយអត់ទេគ្រាន់តែដឹកជញ្ជូនពីនោះម៉ោដើម្បីថា ឥឡូវខាងសេដ្ឋកិច្ចតំបន់ហ្នឹងមានលុយមានកាក់អីដើម្បីបញ្ជូនម៉ោភូមិភាគដើម្បីភូមិភាគចែកចាយចិញ្ចឹមកងទ័ពហ្នឹង គឺថាប៉ុន្តែអ្នកដែលយកហ្នឹងអត់ដឹងចំនួនប៉ុន្មានទេៗ ។

ដានី ៖ បាទ!ចុះអ៊ំមួយទៀតថាកាលហ្នឹង នង សួន មុខមាត់រាងរៅគាត់យ៉ាងម៉េចទៅ?

យ៉េង ៖ វាគាត់ហ្នឹងខ្មៅខ្ពស់ មុខស្រួច ធ្មេញវែងៗ

ដានី ៖ គាត់ខ្មែរខាងជើងដែរឬអត់ទេ?

យ៉េង ៖ បើតាមរឿងហ្នឹងខ្ញុំមិនដឹងថាគាត់ខ្មែរខាងជើង ខ្មែរខាងអីទេ ប៉ុនខ្ញុំតាមដែលខ្ញុំស្តាប់គេនិយាយថាគាត់កាលពីដើមដែលកាលគាត់តស៊ូនៅទីក្រុង គាត់ជាងកាត់សក់ អាហ្នឹងមិនថាពិតមិនពិតៗទេណា៎!

ដានី ៖ បាទៗ!

យ៉េង ៖ ព្រោះខ្ញុំក៏មិនដែលឃើញថាគាត់យ៉ាងម៉េចៗដែរ មិនដែលឃើញគាត់ ហើយឮស្គរប្រវត្តិគេនិយាយថាគាត់ជាងកាត់សក់នៅភ្នំពេញ ។

ដានី ៖ គាត់ខ្មៅខ្ពស់?

យ៉េង ៖ ខ្មៅ ខ្ពស់ ធ្មេញវែងៗ

ដានី ៖ គាត់អ្នកស្រុកណាដែរមើលទៅ?

យ៉េង ៖ ប៉ុន្តែរឿងគាត់មិនដឹងជាខ្មែរកម្ពុជាក្រោមមិនដឹងយ៉ាងណាក៏មិនដឹងដែរ តែប្រពន្ធគាត់នៅខាងព្រៃវែង ស្វាយរៀងនេះ ឈ្មោះ យាយជាៗហ្នឹង ។

ដានី ៖ អ្ហូ!

យ៉េង ៖ មាឌល្អិតយាយជាហ្នឹង

ដានី ៖ បងប្អូនគាត់មានម៉ោធ្វើការអីជាមួយគាត់ដែរឬអត់?

យ៉េង ៖ អត់ដឹងដែរ ។

ដានី ៖ ចុះតា ហួត សេ ?

យ៉េង ៖ តា ហួត សេ ក៏នៅក្នុងអចិន្ត្រៃយ៍ជាមួយគាត់ដែរ

ដានី ៖ មុខ មាត់ រាងរៅយ៉ាងម៉េចដែរ?

យ៉េង ៖ អត់ដឹង ហើយបើតាអីមួយម៉េញដែលខ្ញុំនិយាយម៉េញតា សុខ ប៊ុតចំរើន រាងខ្មៅ មាឌធំក្រអាញ ព្រោះវាពិបាកណាស់ ពិបាកត្រង់ថាយើងជាអ្នកតូចតាច

ដានី ៖ បាទៗ!

យ៉េង ៖ ជំនាន់នោះក៏មិនខុសពីជំនាន់នេះដែរ យើងអ្នកតូចតាចគឺថាមិនអាចទៅចេញចូលបាន តាមចិត្តទេ

ដានី ៖ បាទៗ!ខ្ញុំយល់

យ៉េង ៖ អញ្ចឹង!លុះត្រាណាកន្លែងណាធ្លាប់ដែលថាដឹងថា នៅកន្លែងហ្នឹងគឺយើងចេញចូលបាន ។

ដានី ៖ ចុះដែលថាជីដូនមួយរបស់អ៊ីឈ្មោះ តាសុខនោះ គាត់ជាអ្នកស្រុកកំណើតនៅជាមួយ អ៊ីដែរនៅពោរទន្លេដែរ?

យ៉េង ៖ នៅវាចេះ បើនិយាយពីជីវៈប្រវត្តិរបស់ឪពុកគាត់ៗទាហានបារាំង ហើយដល់ក្រោយ ម៉ោឪពុកគាត់យួនគាត់កាលដែលគាត់នៅតូច បើនិយាយអញ្ចឹងទៅវាក្នុងលក្ខណៈជំនឿ លើមន្តអាគម កាប់គាត់ក៏កាប់មិនដាច់ហើយនេះគាត់ក៏ស្រែជេរថាឯងកាប់យ៉ាងនេះ ងាប់កូនអញហើយអាចោរម្រាយ ចាក់ទៅមួយកាំបិតដាច់ពោះវៀន ដល់អញ្ចឹងគេ យកគាត់ទៅព្យាបាលរហូតដល់ភ្នំពេញ ជំនាន់នោះខ្ញុំនៅតូចៗ ។

ដានី ៖ បាទ!

យ៉េង ៖ ដល់ហើយទៅ អាពោះវៀនគាត់វាសើរើគាត់ស្លាប់មុនយើងធ្វើរដ្ឋប្រហារ ដល់ទៅ គាត់រៀនសូត្រអីបានធ្វើគ្រូបង្រៀន ប្រវត្តិគាត់តាសុខហ្នឹង ។

ដានី ៖ ស្រុកគាត់នៅពោរទន្លេដែរ?

យ៉េង ៖ ស្រុកកំណើតខាងឪពុកគាត់នៅឃុំពោរបាទ នៅកោះធំ អាហ្នឹងវាមានកោះ២ អាមួយ គេហៅកោះថ្មី អាមួយគេហៅកោះធំ កោះធំវានៅខាងក្រោមកោះថ្មី អាភូមិកោះធំ នៅកន្លែងផ្ទះខ្ញុំហើយ ។

ដានី ៖ បាទ!អញ្ចឹងអ៊ំធ្វើនិរសានៅកន្លែងមន្ទីរតំបន់២៥ហ្នឹងរហូតដល់ពេលណាទៅ?

យ៉េង ៖ បាទ!ដល់ហ្នឹងគឺថាក្រោយពីហ្នឹងម៉ោខ្ញុំមិនបានដាចាំខែចាំថ្ងៃទេ ដល់អញ្ចឹងគឺកាលនោះវាមានការដ្ឋានធ្វើស្រែស្ទូងស្រូវ ដល់អញ្ចឹងខ្ញុំចាស់ជាងគេ គេដកខ្ញុំឲ្យម៉ោកាន់កាប់កម្លាំងកងនារី កងយុវ៉ាន់អីម៉ោស្ទូងស្រូវ អាហ្នឹងមិនមែនដកថាកម្លាំងហ្នឹងមានសមាសភាពមិនល្អគេដកឲ្យមកធ្វើទេ គេដកធម្មតា ។

ដានី ៖ គេអ្នកដកធម្មតាដោយសារតែអ៊ំចាស់ ។

យ៉េង ៖ ហ្នឹងហើយអ្នកដែលធ្វើហ្នឹងក៏ថាមានមានសមាសភាពអីខុសឆ្គងអីដែរពួកខ្ញុំហ្នឹង គេចាត់កម្លាំងឲ្យមកធ្វើស្រែៗ ដល់ធ្វើស្រែអញ្ចឹងទៅ ម៉ារយៈស្រូវហ្នឹងវាបានច្រូតខ្លះ មិនទាន់បានច្រូចខ្លះ ដល់ខែដើមឆ្នាំនេះគេដកខ្ញុំទៅ ព្រោះថាខ្ញុំវាមានមុខជំនាញដូចថាជួសជុលទូកអីដែលចាស់ៗប៉ះបិនវាទុកប្រើវានៅខែវស្សា ដល់គេដកខ្ញុំហ្នឹងម៉ោខ្ញុំក៏ទៅធ្វើទៅធ្វើហើយ ជួសជុលបានទូក៦-៧ ដល់បាន៦-៧គេវ៉ៃនៅយើងបន្ទាយខ្មុមសំណរបន្ទាយខ្មុមសំណរហ្នឹងគេចាប់ទាហានមកដាក់នៅខាងផ្សា នៅត្រើយខាងលិច ។

ដានី ៖ ត្រើយខាងលិចនៅក្រោមលើកដែកហ្នឹង?

យ៉េង ៖ អត់ទេ!នៅលើលើកដែក នៅផ្សារព្រែដាច់ មានមន្ទីរកសិកម្ម

ដានី ៖ កាលហ្នឹងតាំងពីឆ្នាំណា?

យ៉េង ៖ វា ខ្ញុំនិយាយហ្នឹងវាវិលចុះវិលឡើងៗព្រោះខ្ញុំចាំអត់បាន ខ្ញុំមិនដឹងថាឆ្នាំ៧១ឬក៏៧២ ទេ ដល់ទៅអញ្ចឹងទៅ ខ្ញុំក៏ទៅអត់ធ្វើអីទេ គ្រាន់តែទៅមើលតែគេ ហើយក៏មិនដឹងថាខ្លួនឯងមានតួនាទីអីដែរ ។

ដានី ៖ នៅធ្វើកងទ័ពទេកាលហ្នឹង?

យ៉េង ៖ អត់ទេ!ឈប់ហើយ ឈប់ត្រឹមខ្ញុំថាឃួនដកកាំភ្លើងលែងកងទ័ពហើយ ត្រឡប់មកនិរសាវិញ ត្រឡប់ពីនិរសាទៅធ្វើស្រែ ត្រឡប់ពីធ្វើស្រែទៅធ្វើទូក ត្រឡប់ទៅនៅហ្នឹងបានប្រហែលជា១ខែ នង សួន បានឡើងទៅមន្ត្រីក្រសួងកសិកម្ម ។

ដានី ៖ បាទ!មន្ត្រីក្រសួងកសិកម្មហ្នឹងនៅណា?

យ៉េង ៖ ដល់គាត់ឡើងមន្ត្រីក្រសួងកសិកម្មហ្នឹង គេហៅខ្ញុំយកម៉ោ ហៅម៉ោកាលហ្នឹងផ្លាស់ប្តូរគណៈតំបន់ហើយ ឡើង ហួត សេ ។

ដានី ៖ ហួត សេ គាត់ឡើងគណៈតំបន់វិញ?

យ៉េង ៖ បាទ! ឡើងគណៈតំបន់ ដល់អញ្ចឹងទៅឡើងម៉ោគេធ្វើការដ្ឋានមួយនៅគេហៅ អន្លុងវែង នេះ ។

ដានី ៖ អន្លុងវែង កំពតនេះ?

យ៉េង ៖ ស្រុកលើកដែក អន្លុងវែងស្រុកលើកដែក ផ្លូវកៀនស្វាយចុះទៅ គេហៅថាវាទៅក្នុង ឃុំបន្ទាយដែក ប៉ុនចុះតាមផ្លូវបែកម៉ោក្នុងម៉ោធ្វើស្រែហ្នឹង ។

ដានី ៖ អញ្ចឹងក្រសួងកសិកម្មនៅម្តុំហ្នឹងវិញ?

យ៉េង ៖ បាទ! ម៉ោធ្វើស្រែ

ដានី ៖ មុនបែក៧៥?

យ៉េង ៖ ហ្នឹងហើយ មុនបែក៧៥

ដានី ៖ ចុះយ៉ាងម៉េចទៀត?

យ៉េង ៖ ធ្វើហ្នឹងហើយ គេបញ្ជូនខ្ញុំម៉ោ អាហ្នឹងនិយាយពីប្រវត្តិរបស់នង សួន ហ្នឹងគាត់ទៅ ប៉េកាំង ហ្នឹងរំដោះពេញហើយ ទៅប៉េកាំងប៉ុន្តែមានមេខ្លះគាត់និយាយចេះ គាត់ និយាយថាគេមិនឲ្យទៅជួបស្តានទូតយួននៅប៉េកាំង ប៉ុន្តែគាត់ឆ្លៀតឱកាសទៅជួបស្តាន ទូតយួននៅប៉េកាំង ។

ដានី ៖ អ្ហូ!

យ៉េង ៖ ដល់ពេលគាត់ត្រឡប់មកវិញ ខ្ញុំក៏អត់ដឹងថាយ៉ាងម៉េចដែរ គេប្រាប់ថាអ្នកខ្លះគេ និយាយថា នង សួន ទៅពេទ្យចិនគេពិនិត្យទៅឃើញថា មហារីកបេះដូង ប៉ុនដល់ ក្រោយម៉ោខ្លះថាម៉ោគ្រាន់តែចុះពីយន្តហោះដល់គេស្ទុកយកបាត់ទៅ

ដានី ៖ មិនដឹងយកទៅណាទៅ?

យ៉េង ៖ មិនដឹងថាយកទៅណាបាត់ទៅ បាត់តាំងពីហ្នឹងរហូតទៅ

ដានី ៖ បាត់តាំងពីឆ្នាំណា?

យ៉េង ៖ ខ្ញុំអត់ចាំឆ្នាំ ខ្ញុំមិនបានគិតគូរអារឿងបញ្ហាហ្នឹងផង

ដានី ៖ បែកឆ្នាំ៧៥ហើយ?

យ៉េង ៖ អាហ្នឹងវាមិនដឹងជា៧៥-៧៦ឬ៧៧ទេដែលគេចាប់ នង សួន ហ្នឹង ព្រោះអាហ្នឹងគឺខ្ញុំ មកនៅការដ្ឋានហ្នឹងគឺចប់សព្វគ្រប់អស់ហើយ ។

ដានី ៖ កាលហ្នឹងអ៊ំមកទទួលធ្វើខាងអីវិញទៅកាលហ្នឹង?

យ៉េង ៖ ខ្ញុំអត់មានទទួលខាងអីទេ ដូចខ្ញុំជំរាបហើយថាកាលដែលគេបញ្ជូនខ្ញុំម៉ោធ្វើស្រែហ្នឹង គ្រាន់តែតួនាទីចាស់ មកមើលការខុសត្រូវដឹកនាំធ្វើតែបណ្ណឹងទេ!

ដានី ៖ បាទ!

យ៉េង ៖ ដល់ពេលមកនៅអន្លង់វែងនេះ កន្លែងការដ្ឋានហ្នឹងតួនាទីខ្ញុំគឺថាបើនិយាយទៅគឺឯករាជ្យ បាទ!ឯករាជ្យត្រង់ថាត្រូវធ្វើនន្លលធ្វើនន្លល ត្រូវធ្វើរនាសធ្វើរនាស ធ្វើគប់ធ្វើគប់ឲ្យ គេ ហើយចុះទៅមើលគេថានន្លលហ្នឹងគួរស្រួលមិនស្រួលអី តែប៉ុណ្ណឹង ។

ដានី ៖ ចុះប្រពន្ធកូនម៉ោនៅនេះដែរ?

យ៉េង ៖ ប្រពន្ធកូន ដល់ពេលខ្ញុំឡើងមកនៅការដ្ឋាននៅកន្លែងនេះមិនដឹងឆ្នាំប៉ុន្មានទេ ម៉ោយក គាត់ទៅ គេឲ្យយកទៅ គេមកយកគាត់ប៉ុន្មានលើកប៉ុន្មានសារហើយ គាត់មិនហានទៅ គាត់ខ្លាច ព្រោះខ្លាចប្ដីគេច្រើនយកទៅបាត់ៗ!

ដានី ៖ បាទ!

យ៉េង ៖ ដល់អញ្ចឹងអត់ឃើញប្ដីគាត់មិនព្រមទៅ ដល់អញ្ចឹងខ្ញុំម៉ោៗយកគាត់ទៅ ប៉ុនមិនដឹងថា គាត់នៅចាំឆ្នាំដែលខ្ញុំម៉ោយកគាត់ទៅឬអត់ ខ្ញុំអត់ចាំ ដល់ទៅហើយ ដល់គេចាប់ នង សួន ហ្នឹងហើយបានគេបញ្ជូនខ្ញុំម៉ោភ្នំពេញ ខ្ញុំម៉ោមុនគេឲ្យជួសជុលផ្ទះជួសជុលអីនៅ បឹងសំយ៉ាបនេះ ដើម្បីឲ្យកម្លាំងនៅ ។

ដានី ៖ បាទ!

យ៉េង ៖ ដល់ពេលបញ្ជូនកម្លាំងពីការដ្ឋានហ្នឹងឡើងទៅភ្នំពេញ គេបែងចែកនៅកសិកម្មនៅខាង រោងចក្រ នៅបឹងសំយ៉ាបនេះមួយកន្លែង នៅព្រែកក្នោនេះមួយកន្លែង ដល់ពេលនេះ ទៅគេដក់ខ្ញុំចេញពីហ្នឹងឲ្យមកនៅព្រែកក្នោ ម៉ោដល់ព្រែកក្នោគេសងវត្តព្រែកក្នោមួយ ហ្នឹងគេរូសចេញអស់ហើយ តាំងគេធ្វើរោងសម្រាប់តំឡើងកាណូត កាណូតហ្នឹងបើ យើងដាក់ចំណុះតាមធម្មតាវាបានលើសហ្នឹង គេដាក់ចំណុះតែ៧០តោនទេ ។

ដានី ៖ បានតែ៧០តោនទេ?

យ៉េង ៖ បាទ!ស្រណុកដឹកតាមទន្លេមេគង្គទៅវែងសែ ព្រោះវាតូចទៅក្រចេះទៅអី ដល់ខ្ញុំទៅ ដល់ហ្នឹងគេបញ្ជូនខ្ញុំទៅព្រែកក្នោនោះបានតែពីរ ដូច៤យប់ឬ៥យប់ទេគេបញ្ជូនខ្ញុំទៅ ក្រចេះ ។

ដានី ៖ បញ្ជូនអ៊ំទៅក្រចេះ?

យ៉េង ៈ បាទ!មិនបញ្ជូនតែខ្ញុំទេ វាមានច្រើនគ្នា២០០០នាក់ជាង បញ្ជូនទៅកាប់ឈើធ្វើគំឡើង កាណូតកប៉ាល់ហ្នឹង!

ដានី ៈ បាទ!

យ៉េង ៈ ដល់ទៅកាប់ឈើនៅក្រចេះហ្នឹងបានក៏កាប់ឈើនៅក្រចេះហ្នឹង កាប់ហើយបានបូកសរុបចំនួនទៅបាន២៥០០កំណាត់ ២៥០០ដើមហើយឈើហ្នឹងចោលហើយ អត់បានដឹកបានអីទេ ដល់អញ្ចឹងវាកើតបដិបក្សជាមួយបក្សនឹងបក្ស ប៉ុល ពត ជាមួយ មេកុយ ធួន ហ្នឹងមេៗ ដល់អញ្ចឹងទៅ គេយោធាគេដេញខ្ញុំចេញពីព្រៃ ពួកខ្ញុំគេហៅក្រសួងដើងទឹក!

ដានី ៈ បាទ!

យ៉េង ៈ បាទ!ដេញខ្ញុំចេញពីព្រៃ គេឲ្យចេញទាំងយប់ហ្នឹង ដល់អាមេកងនោះគ្នាអង្វរៗថាបើឲ្យខ្ញុំចេញទៅតើមានអី កាំបិតពូថៅ ចាន ឆ្នាំងអីបានអីហូប អញ្ចឹងសូមអង្វរចាំព្រឹកចាំឲ្យឡានដឹកចេញម៉ោ ដល់ឡានដឹកចេញម៉ោ ម៉ោដល់ក្រចេះអត់នៅក្រចេះទេ ឡើងមកនៅលើក្រចេះគេហៅថ្មគ្រា មកនៅហ្នឹងបានចំនួនប្រហែលកន្លះខែ ក៏ពីភ្នំពេញនេះឲ្យដឹកអង្ករយកទៅឲ្យប្រហែលជាចំនួន៥០បាវនោះ ការប៉ាន់ស្មានប្រហែលចំនួន៥០បាវ អញ្ចឹងគឺថានៅកន្លែងហ្នឹងរដ្ឋអំណាចក៏គេដ្កត់ដ្កង់ម្ហូបចំនីឲ្យមុននឹងរដ្ឋដឹកអង្ករយកទៅឲ្យ ដល់ដឹកយកទៅឲ្យបានប្រហែលជា៣ថ្ងៃ ស្រាប់តែពីភ្នំពេញនេះ យកកាណូត២ទៅ លីអង្ករចុះមកវិញឲ្យកម្លាំងត្រឡប់មកទីក្រុងភ្នំពេញវិញ ហើយគ្រាន់តែហាមថាបើគេបាញ់គេបោះអីក៏ដោយកុំត បើកតែទៅខាងលិចទៅ ទៅដល់ភ្នំពេញចាំបុកក្បាលចូលកុំឲ្យចូលកន្លែងណាផ្សេង អាហ្នឹងខ្ញុំនិយាយតាមដំណើរហ្នឹងទៅ ។

ដានី ៈ បាទ!

យ៉េង ៈ ដល់ពេលហ្នឹងត្រឡប់មកដល់ភ្នំពេញហើយ ក៏គាត់ឲ្យម៉ោនៅកន្លែងដដែលវិញ ហើយក្រោយម៉ោគាត់ឲ្យមកកាប់ឈើនៅខាងកំពង់ធំនេះ ។

ដានី ៈ ពីណាគេអ្នកឲ្យ គាត់ហ្នឹង?

យ៉េង ៈ ខាងក្រសួងដើងទឹកហ្នឹង ខ្ញុំមិនសូវចាំឈ្មោះគាត់ដែរ ប៉ុន្តែគាត់ហ្នឹងក៏គេចាប់ដាក់គុកដែរ

ដានី ៈ ទូច ភឿន?

យ៉េង ៈ អត់ទេ!មាឌខ្មៅ ក្រអាញដូចខ្ញុំអញ្ចឹង

ដានី ៈ ខាងក្រសួងគមនាគមន៍?

យ៉េង ៖ ខាងក្រសួងដើងទឹក គេហៅក្រសួងដើងទឹក ឈ្មោះ ម៉ន

ដានី ៖ ម៉នហ្នឹងគាត់អ្នកទទួលខុសត្រូវ?

យ៉េង ៖ បាទ!ទទួលខុសត្រូវកន្លែងរោងតំឡើងកប៉ាល់

ដានី ៖ បាទ!

យ៉េង ៖ គាត់ចាំទទួលខាងមុខសញ្ញាហ្នឹង គាត់នាំខ្ញុំទៅកាប់ឈើៗហ្នឹងបានដឹកឈើហ្នឹង យកម៉ោតំឡើងកប៉ាល់ ។

ដានី ៖ បាទ!

យ៉េង ៖ ដល់ហើយទៅ ឈប់ពីកាប់ឈើនឹងម៉ោ គេឲ្យខ្ញុំនៅកន្លែងហ្នឹងគឺមានកម្លាំងមួយក្រុម ប៉ុនមានមេកងមួយគេលើខ្ញុំទៀត ខ្ញុំអត់មានតួនាទីអីទេ មេកងមួយក្រុមខ្ញុំនឹងគឺដឹកឈើ ក្តារ ដឹកឈើកុងអីយកមកឲ្យគេតំឡើងកប៉ាល់ គេឲ្យឡើងម៉ាស៊ីនមួយទេ ដល់ក្រោយមកទៀតហើយខ្ញុំវាអត់មានគិតថាអារឿងគេធ្វើគេដក ចេញគេដកចូល ថាខ្ញុំវាមានបញ្ហានិន្នាការខ្ញុំអត់មានគិតទេ គេដកខ្ញុំម៉ោឲ្យយាយខ្ញុំនេះ ឲ្យគាត់ទៅធ្វើអំបោះធ្វើក្រមាយើង ហើយខ្ញុំហ្នឹងគេឲ្យខ្ញុំទៅធ្វើកីរ កីរតម្បាញអាគ្របយើង គ្របបន្ទុះនោះឲ្យទៅធ្វើហ្នឹង ។

ដានី ៖ ដកហ្នឹង ដកចេញពីកន្លែងធ្វើកប៉ាល់ម៉ោទៀត?

យ៉េង ៖ បាទ!ដកកន្លែងធ្វើកប៉ាល់មកជួសជុលហ្នឹង ជុសជុលនៅកន្លែងត្បាញបានដំណើរការបានច្រើនហើយ ដល់ហើយ មិនដឹងខែប៉ុន្មានខ្ញុំអត់ចាំ គេដកចេញដកចូលអីខ្ញុំអត់មានចាំខែចាំថ្ងៃអីទេ គេដកខ្ញុំទៅ៣នាក់ គេថាឲ្យបងឯងទៅមើលដីស្រែៗកាលហ្នឹង គេឲ្យអង្គភាពមួយៗតាមផ្នែកមួយៗដើម្បីផលិតផ្គត់ផ្គង់ខ្លួនឯង ជួយអង្គភាពកុំឲ្យវាធ្ងន់ទៅ លើរដ្ឋយើងអាចធ្វើទៅបានយើងធ្វើទៅណា៎ អញ្ចឹងខ្ញុំទៅមើលស្រែ មើលស្រែហើយ ទៅក៏

ដានី ៖ មើលស្រែនៅណា?

យ៉េង ៖ នៅអន្លង់ក្ងាន ព្រែក្អោ ទៅមើលស្រែៗហើយគេឲ្យខ្ញុំ៣នាក់ទៅនៅហ្នឹង ប៉ុនស្រែហ្នឹងមិនទាន់បានធ្វើស្រែទេ បានទៅគ្រាន់តែបានដាំតាឡូងដាំអី ដំលូងហ្នឹងដាំតាឡូងហើយ មិនទាន់បានហូបទៀត ប៉ុនមើមប៉ុនៗហើយមើមល្មមហូបហើយ ។

ដានី ៖ តាឡូងអី?

យ៉េង ៈ  តាឡូងផ្ទារយើង ដល់ប្រាប់មេគ្រប់គ្រងទៅ ឥឡូវគេថាយើងនៅកំពុងសំបូរណាស់ កំអាលចាំយើងនេះចាំយើងគាស់យកទៅឲ្យមិត្តយើងហូប ព្រោះឥឡូវយើងសំបូរ មិនទាន់អាត់ខាត់អីណាទេ ។

ដានី ៈ  បាទ!

យ៉េង ៈ  ដល់ហើយម៉ោមិនបានប៉ុន្មានខែប៉ុន្មានថ្ងៃ ព្រឹត្តិការណ៍កើតឡើង អានេះខ្ញុំនិយាយវាចន្លោះខ្លះៗ

ដានី ៈ  បាទ!

យ៉េង ៈ  ព្រឹត្តិការណ៍កើតឡើងហ្នឹងគឺថាឲ្យជីកត្រង់សេទាបៗ អត់មាននិយាយប្រាប់អីទេ គ្រាន់តែឲ្យជីកត្រង់សេទាប ខ្លះក៏ជីកត្រង់សេហើយ ខ្លះក៏មិនទាន់បានជីក តោះយើងឥឡូវត្រូវដកចេញពីកន្លែង ត្រូវទៅនៅកំពង់ឆ្នាំងមាំអាទិត្យ ខ្ញុំកុំអីមិនបែកពីយាយពីកូនពីចៅអញ្ចឹងដែរ ខ្ញុំថាឥឡូវឯងទៅៗ អញនៅចាំកន្លែងចាំមើលៗវាយ៉ាងម៉េចអីយ៉ាង ម៉េចបើថាម៉េចៗចាំអញជិះកង់ទៅតាមក្រោយ ទុកកង់មួយ ។

ដានី ៈ  ប្រាប់ប្រពន្ធ កូនថាអញ្ចឹង?

យ៉េង ៈ  ប្រពន្ធអត់មានបានជួបទេ ជួបតែអាក្រុមក្មេងៗជាមួយខ្ញុំហ្នឹង ដល់ខ្ញុំម៉ោដល់កាណូតវាមិនព្រម វាចាប់ទាញឡើងកាណូតម៉ោ ទាញឡើងកាណូតម៉ោក៏ម៉ោជាមួយគ្នារហូតមកទល់ដល់កំពង់ឆ្នាំង ដូចមិនទាន់ដល់កំពង់ឆ្នាំងទេ គ្រាន់តែម៉ោដល់ខាងលើព្រែកក្ដាមយន្តហោះទំលាក់ដាក់អាមេគន្ធមួយ ។

ដានី ៈ  យន្តហោះយួន?

យ៉េង ៈ  មិនដឹងយន្តហោះពីណា ព្រោះខ្ញុំអត់ដឹងថារបស់យួនឬរបស់អ្នកណាទេ ។

ដានី ៈ  ឆ្នាំណាឆ្នាំ៧៩ហ្នឹង?

យ៉េង ៈ  ហ្នឹងហើយឆ្នាំ៧៩ ដេញទ័ពចេញពីក្រុង យន្តហោះពីរគ្រឿងដាក់គ្រីបឆេះហុយល្មោមអាមួយឡើងម៉ោដល់លើព្រែកក្ដាម ដល់យប់ម៉ោងប្រហែលជា៧មកដល់កំពង់ឆ្នាំងផ្សារក្រោមហ្នឹងក៏ចូល ប៉ុន្តគ្នានដឹងទេធម្មតាគ្មានដឹងថាអីទៀត ម៉ោតែខ្លួនទទេដៃទទេហ្នឹងហើយកូន២នាក់ អានេះមួយ ហើយអាមួយទៅនៅសៀមរាបនោះ ។

ដានី ៈ  បាទ!ចុះអ៊ំពេលអើ បងជីដូនមួយរបស់អ៊ំតា សុខ ជាមេបញ្ជាការយោធាតំបន់២៥យ៉ាងម៉េចដែរ?

យ៉េង ៈ  អាហ្នឹងគេចាប់កាលវ៉ៃរំដោះភ្នំពេញហើយយកទៅបាត់ ។

ដានី ៈ រំដោះភ្នំពេញហើយគេចាប់?

យ៉េន ៈ បាទ!

ដានី ៈ មូលហេតុអីបានគេចាប់គាត់?

យ៉េន ៈ មិនដឹង! បើតាមការពិតៗតាមដែលយើងឮគេថាវាសុទ្ធតែខ្មែរយួន គាសុខ ខ្មែរយួន ប៉ុនដឹខ្ញុំមើលសៀវភៅ គេស្រាវជ្រាវចងក្រងទៅឃើញថាអ្នកដឹកនាំតស៊ូសុទ្ធ តែខ្មែរយួនទាំងអស់ សៀវភៅហ្នឹងកំពសនេះ ។

ដានី ៈ អញ្ចឹង! សៀវភៅហ្នឹងនៅណា?

យ៉េន ៈ សៀវភៅគេបោះពុម្ពរបស់អន្តការគេស្រាវជ្រាវ តាំងពី ប៉ុល ពត តាំងពីនួន ជា តាំងពីអី បើតាមការពិតវាមានតែ ខៀវ សំផនមួយទេដែលជាខ្មែរសុទ្ធ ។

ដានី ៈ អ៊ូ! អញ្ចឹង

យ៉េន ៈ ហើយ អៀង សារី គាត់កម្ពុជាក្រោម ហើយនេះដែលស្លាប់

ដានី ៈ សុន សេន?

យ៉េន ៈ សុន សេន ហ្នឹងក៏កម្ពុជាក្រោម ហីបើប៉ុល ពត ហ្នឹងគាត់នៅតាម

ដានី ៈ ចុះដោយសារតាមអីដឹងប្រវត្តិហ្នឹងថា សុខ ហ្នឹងត្រូវជាបងជីដូនមួយ គាត់ខ្មែរយួនមែនឬក៏យ៉ាងម៉េច?

យ៉េន ៈ មិនដឹងខ្ញុំក៏មិនដឹងដែរ ប៉ុន្តែគ្រាន់តែថាគាត់ជាចូលតាមរយៈណា ប៉ុនគាត់ជាអ្នករៀន គាត់មិនដឹង ខ្ញុំមិនដឹង ព្រោះគាត់ស្គាល់តាំងពី នង សួន ស្គាល់តាំងពីអីណា ដូចខ្ញុំនិយាយអញ្ចឹងសុទ្ធតែខ្មែរសន្តានរបស់គាត់ មិនដឹងថាខ្មែរហ្នឹងជាខ្មែរយួនពិតឬក៏យ៉ាង ម៉េច ប៉ុនដឹឃើញឃើញសៀវភៅគេ គេថាអាហ្នឹងគឺថាបើឈ្មោះអ្នកណាគឺយួនទាំងអស់

ដានី ៈ គេថាអញ្ចឹង?

យ៉េន ៈ បាទ!

ដានី ៈ ចុះសៀវភៅហ្នឹងមាននៅផ្ទះអីដែរឬអត់?

យ៉េន ៈ អត់ទេខ្ញុំមើលសៀវភៅគេនោះ ។

ដានី ៈ មើលសៀវភៅពីណាគេ ផ្ទះពីណា?

យ៉េន ៈ អាក្មួយវាបានពីណាម៉ោ ឥឡូវមិនគេយកទៅណាឬក៏នៅទេ ខ្ញុំមិនដឹង ព្រោះវាបាត់យូរហើយ ព្រោះសៀវភៅហ្នឹងគេចងក្រង ។

ដានី ៈ ចុះអឹដល់ពេលគេចាប់គាសុខ ចាប់អីអញ្ចឹងទៅ ដូចថាអឹជជាជីដូនមួយជាសាច់ញាតិ

របស់គាត់អញ្ចឹងដូចថាអ៊ំអត់មានបញ្ហាអីទេ?

យ៉េង : ខ្ញុំអត់មានបញ្ហាអីទេ ក៏ប៉ុន្តែបើនិយាយទៅវាបងខ្ញុំបងថ្លៃខ្ញុំ បងប្រពន្ធខ្ញុំបង្កើតហ្នឹងក៏គេចាប់មួយដែរ ។

ដានី : គាត់ខាងអីដែរ?

យ៉េង : ខាងទាហាន

ដានី : ខាងទាហានអីគេ?

យ៉េង : ទាហានខ្មែរក្រហមហ្នឹង ប៉ុន្តែគាត់មេកងពល ។

ដានី : គាត់ឈ្មោះអី?

យ៉េង : ដួង ស្រេង

ដានី : គាត់នៅខាងកងពលណា?

យ៉េង : កាលនេះនៅកងពល១១ កាលមុនវរៈសេនាធំនៅកងពល១១ ដល់ឡើងម៉ោគេបង្កើតព្រលានកំពង់ឆ្នាំងនេះ ថាចាប់នៅកំពង់ឆ្នាំង ប៉ុនពាក្យហ្នឹងមិនពិតថាគេចាប់ឬក៏យ៉ាងម៉េចទេ ប៉ុនគ្រាន់តែថាឲ្យដឹងថាគាត់ហ្នឹងវាជាប់និន្នាការ ព្រោះ សេក សោម ជាប្រធានកងពលធំនៅសមុទ្រ ។

ដានី : បាទ!ប្រធានកងពលឈ្មោះ តាសោម ។

យ៉េង : បាទ!នៅសមុទ្រជើងទឹក គេថាគាត់ហ្នឹងខ្សែសេក សោម ហើយមួយថាគេចាប់គាត់មួយទៀតគេថាគាត់ដឹងខ្លួនមិនឲ្យគេចាប់ គាត់ដេកឃុំភ្លួយ គាត់ដឹងខ្លួនទាន់ ពាក្យនេះមិនច្បាស់ ឮតែគេថា ។

ដានី : ហ្នឹងបងថ្លៃរបស់អ៊ំ?

យ៉េង : បាទ!បងថ្លៃរបស់ខ្ញុំ

ដានី : ឈ្មោះ ដួង ស្រេង កាលពីកងពល១១គាត់នៅជាមួយតា សោម ហ្នឹង?

យ៉េង : បាទ!សេក សោម ។

ដានី : ចុះតាសោម ដល់ពេលក្រោយម៉ោគាត់ទៅកងពលជើងទឹកនៅសមុទ្រ?

យ៉េង : បាទ!

ដានី : ចុះនៅជាមួយតាមុតដែរឬអត់ទេ?

យ៉េង : អត់ដឹង តាមុត កូនតាម៉ុក?

ដានី : បាទ!

យ៉េន ៖ អត់ដឹងខ្ញុំអត់ដឹងទេ

ដានី ៖ ព្រោះតាមុត គាត់កងពល១៦៤នៅកំពង់សោម

យ៉េន ៖ បាទ!

ដានី ៖ ពេលបែក៧៥ហើយ

យ៉េន ៖ បាទ!ខ្ញុំអត់ដឹងទេ ព្រោះរឿងរ៉ាវហ្នឹង

ដានី ៖ ចុះអ៊ំពេលអើ អញ្ចឹងដល់ពេលក្រោយម៉ោគេផ្លាស់អ៊ំមកនៅក្រសួងកសិកម្មជាមួយ តា នង សួន ?

យ៉េន ៖ បាទ!

ដានី ៖ អញ្ចឹងពេលបែក៧៥ហើយយ៉ាងម៉េចអ៊ំមកនៅភ្នំពេញ គេផ្ទេរអ៊ំពី?

យ៉េន ៖ បាទៗ!ដល់ពេលគេចាប់នង សួនទៅគេបញ្ជូនម៉ោពេញ គេបែងចែកកម្លាំងហ្នឹង នៅកសិកម្មហ្នឹងម៉ោអាណេង អាណេងហ្នឹងក៏គេចាប់អាណេងទៅនៅបង វ៉ាត អាហ្នឹងផ្ទេរចែកម៉ោ ខ្ញុំឡើងម៉ោខាងក្រសួងដើងទឹក ម៉ោខាងធ្វើកបាល់ធ្វើកាណូតនោះវិញៗ

ដានី ៖ បាទ!ហ្នឹងដាច់ពីក្រសួងកសិកម្មហើយ?

យ៉េន ៖ ដាច់ហើយ

ដានី ៖ ចាប់នង សួន ហើយ គេតំឡើងឈ្មោះ ណេង ?

យ៉េន ៖ បាទ!នង សួន ណេង តាវ៉ាត ៣នាក់ ដល់ចាប់នង សួន ទៅឡើងអាណេងហ្នឹង គេគ្រប់គ្រង បងតាវ៉ាតរង ដល់ចាប់អាណេងហ្នឹងទៀតនៅតែតាវ៉ាតម្នាក់ឯង យួនចូលស្រុកបណ្ដោយៗ

ដានី ៖ បាទៗ!អញ្ចឹងអ៊ំម៉ោដើងទឹក បន្ទាប់ម៉ោផ្លាស់ម៉ោដើងទឹកវិញ?

យ៉េន ៖ បាទ!

ដានី ៖ ម៉ោខាងដើងទឹកឈ្មោះអីគេជាអ្នកគ្រប់គ្រងនៅនោះ?

យ៉េន ៖ ដែលខ្ញុំនិយាយប្រាប់មិញឈ្មោះមនហ្នឹង

ដានី ៖ មនហ្នឹងគាត់ប្រធាននៅហ្នឹង?

យ៉េន ៖ បាទៗ!

ដានី ៖ អ៊ំអត់ដែលឮឈ្មោះ ទូច ភឿន អីទេ?

យ៉េន ៖ អត់ទេ!អត់ដែលទេ

ដានី ៖ ចុះកាលហ្នឹងអ៊ំដែលជួបអ៊ំដែរឬអត់?

យ៉េង ៖ អ៊ំៗខ្ញុំជួប អ៊ំ ខៀវ សំផន

ដានី ៖ ជួបគាត់ពេលណា?

យ៉េង ៖ ពេលដែលគាត់ម៉ោមើលកូនចៅដែលឈូសក្តារ ឈូសអី

ដានី ៖ កាលហ្នឹងគេរូសវត្តណាមួយ ដែលអ៊ំនិយាយហ្នឹង?

យ៉េង ៖ រូសហ្នឹងមិនដឹងគេរូសតាំងពីជំនាន់ប្រជាជាតិហ្នឹងម៉ោបុក៏យ៉ាងម៉េចទេ កន្លែងព្រែកភ្នៅ បើខ្ញុំម៉ោឃើញគេធ្វើរោងចក្រតំឡើងកប៉ាល់ហើយ ។

ដានី ៖ តែវត្តហ្នឹងអត់មានវត្តទេ?

យ៉េង ៖ អត់!រូសវត្តអស់ហើយ នៅសល់តែសាលាគេធ្វើដូចព្រះវិហារនៅសល់មួយ ។

ដានី ៖ តែវត្ត វិហារហ្នឹងគេរូសហើយ?

យ៉េង ៖ នៅសល់តែមួយហ្នឹង

ដានី ៖ កាលហ្នឹងអ៊ំ ខៀវ គាត់ទៅមើលកូនចៅនៅឈូសឈើហ្នឹងដែរ?

យ៉េង ៖ បាទ!គាត់ចូលទៅមើលឃើញតែម្តងហ្នឹងទេ ។

ដានី ៖ គាត់មាននិយាយអីបុអត់?

យ៉េង ៖ គាត់អត់មាននិយាយអីទេ ប៉ុនពេលដែលនេះហ្នឹងខ្ញុំអត់បានជួបទេ តែថាគាត់សួរកូនចៅហ្នឹងគាត់សួរអំពីបញ្ហាហូបចុក ការហូបចុកហ្នឹងគឺថាមិត្តការហូបប៉ុណ្ណឹងគឺហូបគ្រាន់ដែរបុទេ? ក្មេងនិយាយប្រាប់ថា អ្នកខ្លះឆ្លើយថាមិនគ្រប់គ្រាន់ទេ បើអ្នកហូបតិចហ្នឹងគ្រប់គ្រាន់ហើយ បើអ្នកហូបច្រើនមិនគ្រប់គ្រាន់ទេ ប៉ុននំប័ុងប៉ុណ្ណឹងប្រវែងមួយគក់ហ្នឹងហើយកាច់ជា២ ប៉ុនគ្រាន់តែថាវាសំបូរម្ហូប នៅកន្លែងខ្ញុំនោះសម្បូរម្ហូប ។

ដានី ៖ ចុះអ៊ំហូបនំប័ុងទេ កាលជំនាន់នោះ?

យ៉េង ៖ បាទ!មុនដំបូង ហូបនំប័ុងៗហើយ បានហូបបាយ ដល់ក្រោយម៉ោអារឿងបញ្ហាអ្នកដែលកម្លាំងធំគេថា បើមិនឆ្អែតក៏ថាឆ្អែតទៅចុះ បើមិនឆ្អែតទៅរកអីណាទៀត អញ្ចឹងគឺថាតែប៉ុណ្ណឹង ដល់គាត់សួរអញ្ចឹងទៅក្រោយម៉ោបានមួយ មួយហ្នឹងអ្នកហូបតិចហូបអត់អស់ទេ ព្រោះអីយើងហូបជាមួយសម្ល ហើយអ្នកដែលនេះហ្នឹងគឺល្មមម៉ង ។

ដានី ៖ ចុះអ៊ំកាលហ្នឹងយ៉ាងម៉េចបានគេឲ្យយើងហូបនំប័ុងអញ្ចឹង ព្រោះខ្មែរយើងទំម្លាប់ហូប បាយ ប៉ុន្តែដល់បេលហ្នឹងគេឲ្យយើងហូបនំប័ុងវិញ កាលហ្នឹងអ៊ំមានដឹងមូលហេតុអីបានគេឲ្យយើងនំប័ុងអញ្ចឹង មិនឲ្យយើងហូបបាយហូបអីតាមទំម្លាប់យើងធម្មតាទៅ ប្រពៃណីពិដូនពីតាតាមទំម្លាប់យើងរាល់ថ្ងៃម៉ោគឺថាយើងហូបតែបាយហ្នឹងពីថ្ងៃ ពីល្ងាច ម៉ោ

យើងហូបតែបាយ?

យ៉េង : អានេះបានជាលោកមានប្រសាសន៍អញ្ចឹងគឺថា អានេះជាទស្សនៈខ្ញុំផ្សេងទៅវិញ ទស្សនៈខ្ញុំផ្សេងខ្ញុំថា អារឿងម៉ាម្សៅដែលវាមាននៅសល់ទុកយូរមមកហើយ បាទៗ! អញ្ចឹងលក្ខណៈដែលសន្សំសំចៃ ព្រោះអង្ករយើងវាទុកទៅបានបន្តទៀត អញ្ចឹងគឺថាអាម៉ាម្សៅហ្នឹងគេត្រូវធ្វើឲ្យហូប ។

ដានី : អញ្ចឹងដោយសារមាននៅសល់ម្សៅ បានគេធ្វើនំប័ុងឲ្យយើងហូប?

យ៉េង : បាទ!អាហ្នឹងទស្សនៈខ្ញុំ ប៉ុនខ្ញុំមិនបានទៅឃើញឃ្លាំងផ្ទាល់ទេ ប៉ុន្តែទស្សនៈរបស់ខ្ញុំថាអញ្ចឹង ។

ដានី : ចុះដល់យើងហូបនំប័ុងជាមួយសម្លអញ្ចឹងយើងអត់ទ្រលាន់ទេ?

យ៉េង : ធម្មតា ខ្ញុំសព្វថ្ងៃនេះក៏អញ្ចឹងដែរ ឲ្យតែបាននំប័ុងមួយម៉ោជាមួយសម្ល សម្លអីក៏បានដែរឲ្យតែសម្ល សម្លប្រហើរក៏បាន ។

ដានី : ជាមួយនំប័ុងហ្នឹង?

យ៉េង : បាទ!ជាមួយនំប័ុង តាមួយហ្នឹងហើយមួយព្រឹកថ្ងៃត្រង់

ដានី : ម្យ៉ាងដែរ!

យ៉េង : បាទ!ប៉ុនគ្រាន់តែថាវាមាន អានេះសារមកវិញវាមានការបែងចែកៗហ្នឹងដូចខ្ញុំនិយាយអញ្ចឹង គ្នាអ្នកកម្លាំងខ្សោយទៅគ្នាហូបគ្រប់ អ្នកដែលកម្លាំងខ្លាំងទៅគ្នាហូបស្ទើរ ព្រោះគេធ្វើលីងសីងប៉ុននេះ ប្រវែងនេះ ។

ដានី : បាទ!ចុះក្រៅពីអ៊ំ ខៀវ សំផន មានអ៊ំណាៗទៀតដែលមកសួរសុខទុកទៀតឬអ៊ំមានដែលបានជួបទៀតឬអត់?

យ៉េង : ខ្ញុំមិនដែលបានទេ ជួបតែអ៊ំ នួន ជា ដែលបានជួប ។

ដានី : ជួបគាត់ធ្វើអីហ្នឹង?

យ៉េង : គាត់ហៅយកទៅរៀនសូត្រ នៅភ្នំពេញហ្នឹងម៉ង បង្រៀនរឿងនយោបាយអី អប់រំ

ដានី : គាត់ហៅអ៊ំៗនៅកន្លែង?

យ៉េង : បាទ!គេហៅតាំងពីមេកង មេក្រុមអី នៅតាមមហាជនអី ហៅទៅដើម្បីទៅរៀនសូត្រ

ដានី : កាលហ្នឹងធ្វើកប៉ាល់អី អ៊ំជាអ្នកមេជាងធ្វើនៅហ្នឹងម៉ង?

យ៉េង : ខ្ញុំមិនមែនមេជាងទេ មេជាងគេផ្សេង ខ្ញុំគ្រាន់តែថាក្នុងចំនែករួមក្នុងការធ្វើហ្នឹង ខ្ញុំគ្រាន់តែដឹកឈើយកទៅឲ្យគេ មានផ្នែកៗរបស់វា អ្នកឈូសមួយផ្នែកទៅ អ្នកអាអ្នក

សម្រាប់ខ្សៀលកុងមួយផ្នែកទៅ អ្នកតំឡើងមួយផ្នែកទៅ។

ដានី : ចុះអ៊ំអ្នកដឹកឈើ?

យ៉េង : បាទ!

ដានី : អ្នកប្រមូលឈើឲ្យគេ?

យ៉េង : បាទ!ទៅដឹកពីរោងចក្រ កន្លែងអាលម៉ោ

ដានី : ដល់ពេលអ្នកគ្រប់គ្រងធំនៅហ្នឹង?

យ៉េង : ឈ្មោះ មន ហើយមេជាងគេឥឡូវហ្នឹង នៅខាង សាមគ្គី។

ដានី : ឈ្មោះអីគេ?

យ៉េង : ភ្លេចហើយ ប៉ុនឥឡូវអាហ្នឹងក៏វានេះដែរឥឡូវធ្វើមេឃុំឥឡូវ ឈ្មោះអាសែន។

ដានី : មេឃុំណា?

យ៉េង : មេឃុំនៅសាមគ្គី

ដានី : ខាងសាមគ្គីខាងណា ខាងសំពៅលូន?

យ៉េង : ខាងសំពៅលូន។

ដានី : ឃុំអីគេ?

យ៉េង : មិនដឹងឃុំអីទេ ទៅដល់គីឡូ១៣ហ្នឹង សួរគេទៅ ប្រធានឃុំគេនៅណាឈ្មោះ សែន ប្រពន្ធគាត់ឈ្មោះពុំ។

ដានី : ចុះអ៊ំកាលជំនាន់ហ្នឹងមានដូចថា អ៊ំនៅភ្នំពេញហ្នឹងអ៊ំមានដឹងថាអ្នកនៅភ្នំពេញបាត់ៗ អ៊ំមានដឹងថាគេចាប់យកទៅសម្លាប់ទេ?

យ៉េង : កាលហ្នឹងគឺថាមិនដឹងថាគេយកទៅសម្លាប់ អត់មានដឹងទេខ្ញុំអត់មានដឹងទេ ប៉ុន្តែគ្រាន់ថាចេះមួយៗកាលដែលខ្ញុំនៅព្រៃកន្ទោ មួយៗទាំងសម្លាប់ទាំងអីអត់ដឹងទេ ដឹងតែថាតែមានទោសគេយកទៅដាក់គុក ដាក់ច្រវ៉ាក់អីហ្នឹងមាន ដឹង តែត្រង់ថាគេយកទៅសម្លាប់ខ្ញុំអត់ដឹងទេ។

ដានី : ដឹងតែមានទោសគេយកទៅ?

យ៉េង : បាទ!ឡានមានឡានឡង់រូវែរមួយ មួយៗឲ្យតែឃើញឡានឡង់រូវែរមកខ្លាចមិនដឹងយ៉ាងណាយ៉ាងណីទេ។

ដានី : ឡានហ្នឹងរាងវាយ៉ាងម៉េច?

យ៉េង : ឡានដូចឡានពួកដែលស៊ីម៉ាក់បើកអាមួយតូចៗហ្នឹង អាហ្នឹងឡង់រូវែរ។

ដានី ៖ ឡានហ្នឹងយ៉ាងម៉េច គេបិទឃ្លាំប្អអត់ទេ?

យ៉េង ៖ វាដូចឡានស៊ីម៉ាក់ហ្នឹងអញ្ចឹងដូចគ្នាអញ្ចឹង ។

ដានី ៖ មកចាប់ទៅ?

យ៉េង ៖ គេហៅទៅធម្មតា

ដានី ៖ ហៅទៅអត់មានចងមានអីទេ?

យ៉េង ៖ អត់

ដានី ៖ ចុះកន្លែងអ៊ំធ្វើការមានគេហៅទៅឡើងឡានដែរប្អអត់?

យ៉េង ៖ មានដែរ ប៉ុនវាខុសគ្នា

ដានី ៖ ចុះអ៊ំភ័យដែរប្អអត់ឃើញឡានគេម៉ោ?

យ៉េង ៖ វាព្រោះខ្ញុំវាចេះ ខ្ញុំនិយាយត្រង់ម៉ង ព្រោះខ្ញុំថាភ័យក៏មិនដឹងភ័យទៅណា ព្រោះខ្ញុំនឹកថាបើខ្ញុំធ្វើអំពើអាក្រក់ វាទទួលបាននូវអាក្រក់ ។

ដានី ៖ អ្ហូ!អ៊ំគិតអញ្ចឹង?

យ៉េង ៖ បាទ!ខ្ញុំម៉ោហ្នឹងប្រវត្តិរូបខ្ញុំហ្នឹង ខ្ញុំដាក់រហូតទល់សមាហរណកម្មខ្ញុំឈប់លែងទទួលការងារអីទាំងអស់ ខ្ញុំដាក់តែអ្នកនាំចូលម៉ោបំរើការងារបំរើតស៊ូហ្នឹងគឺឈ្មោះសុខ នោះជាអ្នកនាំ ។

ដានី ៖ ឈ្មោះ សុខ ដែលថាបងប្អូនជីដូនមួយអ៊ំហ្នឹង?

យ៉េង ៖ បាទ!

ដានី ៖ ដាក់តែអញ្ចឹង?

យ៉េង ៖ ដាក់តែអញ្ចឹងរហូត តែអត់ដែលមានអ្នកណាធ្វើអីខ្ញុំទេ អត់មានអ្នកណារករឿងថាអីចេះចុះអីអត់ ។

ដានី ៖ ប៉ុន្តែអ៊ំមានដឹងថាគេចាប់ តាសុខ អ៊ំនៅហ្នឹងដែរប្អអត់?

យ៉េង ៖ គេចាប់ខ្ញុំនៅហ្នឹង

ដានី ៖ ដឹងឃើញគេចាប់ដែរប្អអត់?

យ៉េង ៖ អត់ឃើញទេ តែខ្ញុំដឹងថាគេហៅយកទៅ

ដានី ៖ ហៅទៅដឹងតែគេចាប់គាត់ហើយ?

យ៉េង ៖ បាទ!ព្រោះរឿងដែលគេហៅយកទៅហើយវាដែលស្លាត់ ទោះបីយ៉ាងណាក៏ដោយ ដូចឥឡូវដូចថាខ្ញុំខ្សឹបខ្សៀវប្រាប់លោក លោកមានស្គាល់មិត្តភក្រទៀតប្រាប់មិត្តភក្រ ទៀត ។

ដានី ៖ តែអ៊ីអត់មានដែលគេហៅទេ?

យ៉េន ៖ អត់មានសោះ រហូតទល់ម៉ោឥឡូវមិនដែលអ្នកណារករឿងខ្ញុំអីចេះចុះអត់ទេ ។

ដានី ៖ ចុះអ៊ីមួយទៀត តាំងពីសម័យអ៊ីចូលគស៊ូរហូតដល់ពេលសម័យ៣ឆ្នាំ កាលអ៊ីនៅភ្នំ ពេញ អ៊ីមានធ្លាប់ជួយពីណាដូចថាគាត់មានបញ្ហាអីត្រូវគេចាប់ ឬក៏ត្រូវគេសម្លាប់អី អ៊ីមានធ្លាប់បានជួយពួកគាត់ឲ្យរួចជីវិតអី អ៊ីមានដែលបានជួយទេ?

យ៉េន ៖ កាលដែលនៅនោះគឺខ្ញុំមិនដែលមានទេ ប៉ុនដែលខ្ញុំមកនៅនេះអាហ្នឹងខ្ញុំមាន ឥឡូវជាក់ ស្ដែងបើថាលោកមិនជឿខ្ញុំមនុស្សនៅរស់ដល់សព្វថ្ងៃនេះ ។

ដានី ៖ បាទ!អ្នកណាគេទៅ?

យ៉េន ៖ ឈ្មោះ កំសត់ រឿងរ៉ាវពីខាងដើមម៉ោខ្ញុំមិនដឹងយ៉ាងម៉េចទេ ប៉ុនគាត់ហ្នឹងនៅ៥១៩ ពីមុន៥១៩នៅខាងជើងនៅខាងជងរែកនោះ កាលហ្នឹងខ្ញុំក៏អត់នៅដែរដែលយួនចូល ទៅនៅដីថៃ អញ្ចឹងគឺថាគាត់ម៉ោ គេបញ្ជូនគាត់ម៉ោរៀនពេទ្យជាមួយមិត្ត កេង នៅ សព្វថ្ងៃនេះ ពេទ្យសព្វថ្ងៃនេះ ។

ដានី ៖ បាទ!

យ៉េន ៖ បាទ!ពេទ្យនៅគស៊ូ ដល់អញ្ចឹងទៅក៏ខ្សែរយៈជាមួយនឹងជនួនខ្ញុំនោះ ធ្លាប់រស់នៅជា មួយ ស្គាល់គ្នា ។

ដានី ៖ ជនួនអ៊ីឈ្មោះអី?

យ៉េន ៖ ឈ្មោះ រដ្ឋ ដល់ស្គាល់គ្នាអញ្ចឹងទៅគាត់មានអ្នកណា មានតែខ្ញុំ ដល់អញ្ចឹងគាត់ម៉ោឲ្យ នៅជាមួយខ្ញុំនឹងទៅ ហើយរៀនសូត្រអីចេញចូលនឹងទៅ ស្រឡាញ់គ្នារាប់អានហ្នឹងទៅ ដល់ហើយទៅគាត់រៀនហើយក៏នៅជាប់នេះទៅ ដល់ហើយទៅគេចោទថាគាត់នេះជួប ជាមួយអីដូចពួកអូស្រ្តាលី ជួបជាមួយសម្ដេចដិះយន្តហោះ ដិះអីណាគេចោទគាត់ គេ ចង់សម្លាប់ដល់អញ្ចឹង សាមនបញ្ជាពីសុខភាព សុខភាពគាត់ទទួលគ្រប់គ្រង ដល់អញ្ចឹង ទៅចាប់គាត់យកមកដាក់មន្ទីរអប់រំ ខ្ញុំក៏នឹងឃើញថាគេចោទប្រកាន់ចេះចុះទៅខ្ញុំក៏ទៅ ព្រោះភាពខ្ញុំហៅតែភាព១ ព្រោះវាប្អូនខ្ញុំហើយវារាប់អានខ្ញុំតាំងពីនៅក្នុងសង្រ្គាមនោះ ។

ដានី ៖ បាទ!

យ៉េន ៖ បាទ!ហើយខ្ញុំទៅសួរដំណើរទំនង ខ្ញុំទៅសួរដំណើរទំនងទៅ គាត់១ថាឥឡូវគេចោទថា រាយការណ៍មកឲ្យខ្ញុំហើយ ឥឡូវទៅជួបអ្នកនេះទៅជួបអ្នកនោះហើយអី១វាទៅដិះយន្ត ហោះជាមួយសម្ដេច ពួកអ្នកគស៊ូមិនខឹងនឹងស្ដេច!

ដានី ៖ បាទ!

យ៉េន ៖ បាទ!ដល់អញ្ចឹងខ្ញុំថាមិនមែនទេអារឿងបញ្ហាហ្នឹង មនុស្សនេះខ្ញុំចាប់ទឹមស្គាល់មកល្អ ណាស់ បើភាពឯងជឿទៅសួរមិត្តកេងទៅ មិត្តកេង តើអ្នកហ្នឹងបានរៀនសូត្រជាមួយ មិត្តកេងដែរឬទេ ព្រោះមិត្តកេងជាប្រធានហ្នឹង ។

ដានី ៖ ខាងពេទ្យ?

យ៉េន ៖ ខាងពេទ្យ ថាគាត់មករៀនសូត្រឬអត់ទេ ហើយបើមិនជឿខ្ញុំទេcallទៅសួរពូអីដែលកុត ដៃអាសយពូអីដែលនៅខាងជើង កងពលធំកុតដៃនោះ គាសារឿន ទៅសួរគាសា រឿនៗគាត់ជាអ្នកចាត់ចែងម៉ោ ឥឡូវពូឯងcallទៅថាតើមនុស្សហ្នឹងវាយ៉ាងម៉េចអី យ៉ាងម៉េច បានខ្ញុំប្រាប់ទៅមិនមែនទេអានេះគេសម្លប់ម៉ង ព្រោះគាត់ហ្នឹងពេទ្យហើយ ខ្ញុំប្រៀបថាថ្នកហ្នឹងទឹកវាថ្លាល្អ មួយៗចូលចិត្តទៅដងទឹកថ្នកហ្នឹងដឹកទៅវាឆ្ងាញ់ ហ្នឹងខ្ញុំ លើកឧទាហរណ៍មកអញ្ចឹង ប៉ុនគាត់អ្នកព្យាបាលហ្នឹងគាត់តាមដានច្បាស់នូវមុខជំងឺ អញ្ចឹងគឺថាអ្នកណាដែលគេយកចិត្តទុកដាក់លើមុខជំងឺហ្នឹង ទៅមើលតាមដានច្បាស់ លាស់ហើយជាគឺថាគេចូលចិត្ត ដល់អញ្ចឹងអាអ្នកលក់ថ្នាំហ្នឹងវាត្រូវបុករុកគ្នា វាត្រូវ មូលប្រកាច់គ្នា ទៅនិយាយវានិយាយទៅខ្ញុំធានាៗរាប់រងក៏ទៅដេញឲ្យចៅហ្វាយស្រុក ឈឹម មន្ទីនេះនៅរងគាត់មិនទាន់ឡើងនេះទេ ខ្ញុំថាឥឡូវ បើបងឯងធានាបើមនុស្ស ហ្នឹងរត់បាត់ខ្ញុំចាប់បងឯងដាក់គុកហើយ ខ្ញុំថាភាពបើអញចេះរត់អញរត់បាត់យូរយាំង ហើយ ប៉ុន្តែអញរត់ទៅមិនដឹងជាអញទៅរកស៊ីអីឥឡូវហ្នឹង ទៅនោះអញទៅរកស៊ី បើ អញរត់អញរត់បាត់ហើយ ប៉ុនថាមិនអីទេឥឡូវបើថាមនុស្សហ្នឹងរត់បាត់អញទទួលខុស ត្រូវ ខ្ញុំសុខចិត្តជាប់គុកជំនួស ក៏វាធ្វើសំបុត្រធ្វើលែងម៉ោ ឲ្យយកម៉ូតូម៉ោ ហើយគេ ដកតាំងពីខ្សែក តាំងពីម៉ូតូទុក គេមិនឲ្យបាត់ ។

ដានី ៖ ខ្សែកអីគេ?

យ៉េន ៖ ខ្សែមាស

ដានី ៖ របស់ពីណាគេ?

យ៉េន ៖ របស់កំសត់ហ្នឹង ដល់ខ្ញុំម៉ោយកខ្សែកខ្សែអី យកម៉ូតូយកអីម៉ោ គេបញ្ជាម៉ោឲ្យលែង អ្នកទោសចេញពីគុក ហ្នឹងមែនៗខ្ញុំជួយ ។

ដានី ៖ ឆ្នាំណាហ្នឹង?

យ៉េន ៖ ខ្ញុំមិនដឹង អាសយម៉ាជំនាន់ដែលគេដកហូតរទេះគោហូតអីហ្នឹង៧០ប៉ុន្មាន ៧៦-៧៧?

ដានី ៖ ៩០ដាងហើយ ពីព្រោះ៧៩យើងរត់ម៉ោ

យ៉េង ៖ ៩០ប៉ុន្មានទេ មុនគេធ្វើរោងគោដាក់រនូងមូលនេះ មិនដឹង៩០ប៉ុន្មានទេ!

សយ ៖ ៩១

យ៉េង ៖ មិនដឹង ៩១-៩២ កាលចាប់អារីពីរឿងគេដកហូតអាត្រាក់ហូតអីមិនឲ្យមាននោះណា៎

សយ ៖ ៩១ហ្នឹងឯង

យ៉េង ៖ បាទ!ជិតាន់ហ្នឹង

ដានី ៖ ម៉េចគេដកហូតអាត្រាក់?

យ៉េង ៖ គឺថា បើកាលណាទុកឲ្យប្រជាជនមាន វាពិបាកប្រើ

ដានី ៖ អ្ហូ!គេថាអញ្ចឹង?

យ៉េង ៖ អាហ្នឹងជាពាក្យអាចាមរាម សុន សេន ជាអាចប្រព័ន្ធ សុន សេន បើប្រជាជនក្រទៅគ្រាន់តែចិញ្ចឹមឲ្យរស់ទៅគឺថាឲ្យធ្វើអីគឺបានឆាប់ចេះ កាលណាប្រជាជនមានត្រូវមានការតវ៉ា បើអញ្ចឹងទេគឺថាវាមិនទៅធ្វើទេ គឺថាវាជួលគេជួលឯងឲ្យទៅធ្វើ អាហ្នឹងរបៀបអញ្ចឹងបើតាមការយល់ ។

ដានី ៖ ហ្នឹងចេញពី សុន សេន ម៉ោគាត់ឲ្យប្រមូល?

យ៉េង ៖ អាហ្នឹងបទបញ្ជាពី សុន សេន ៗគាត់ជាអ្នកគ្រប់គ្រងធំ ។

ដានី ៖ គ្រប់គ្រងធំនៅម្តុំហ្នឹង?

យ៉េង ៖ បាទ!គ្រប់គ្រងនៅតមបន់៣២

ដានី ៖ ចុះម៉េចទៅដល់ពេលអញ្ចឹង?

យ៉េង ៖ ដល់អាហ្នឹងក្រោយម៉ោមិនទាន់អីទេ ដល់ក្រោយម៉ោមិនដឹងជាយ៉ាងម៉េចបានជា កើតទៅជាបែកបាក់គ្នា សុន សេន តាម៉ុក តានួន ជា ម៉ោហៅទៅនោះអត់ជួប អី ឈានដល់នេះមកជួប ភាព ហៅប្រជុំៗរឿងភាព សុំ ឯករាជ្យម្ចាស់ការលើខ្លួនឯង

ដានី ៖ តាភាពគាត់សុំអញ្ចឹងម៉ង?

យ៉េង ៖ បាទ!សុំឯករាជ្យលើខ្លួនឯង ហើយគាត់មិនព្រមបើឲ្យ មិនព្រមបើឲ្យហៅទៅប្រជុំ ពួកកូនចៅអត់ឲ្យទៅប្រជុំទេ ។

ដានី ៖ កូនចៅអត់ឲ្យតាភាពទៅ?

យ៉េង ៖ អត់ឲ្យទៅ ហើយគាហ្នឹងគាត់ចង់ថាហៅ ឈាន ហ្នឹងមិនបានគាត់ថាហៅ ឈាន មិន បាន ប៉ុនភាពថាបើអីចង់ជួបឈានខ្ញុំហៅបាន អញ្ចឹងគឺថាភាពនេះវាធំជាងគាត់ទៀត ហៅឈានមកបាន គាត់ហៅឈានមិនម៉ោ ។

ដានី ៖ គាត់ខឹង?

យ៉េង ៖ បាទ!ហើយគាត់ភាពថាយ៉ាងច្រើនណាស់២០នាទីមកដល់ អញ្ចឹងឲ្យភាពហៅ ភាពហៅ ម៉ោ ថាឥឡូវឈានមកដល់ហើយ អីចង់ជួបទៅជួបទៅនៅដីថៃ អត់ចូលម៉ោទេ ទៅ ជួបនៅដីថៃ អញ្ចឹងបានជាកើតបក្សដិបក្សហ្នឹង ត្រឡប់ទៅវិញទៅ កើតជាមានបាស់ បោរខ្មែរក្រហមនឹងខ្មែរក្រហមប្រទូសប្រទាស់គ្នាមិនបាននេះទេ ។

ដានី ៖ បាទៗ!

យ៉េង ៖ លើកទ័ពម៉ោព្រំប្រទល់នោះ ប៉ុនឯនេះចាប់រថក្រោះបាន២គ្រឿងហើយ អាររថក្រោះ ខាងនោះមកឈរនៅខាងដីនេះ ប៉ុនអត់ធ្វើអីទេ ទៅចាប់យកតែរថក្រោះ កម្លាំងអត់ មានធ្វើអីទេឲ្យទៅ កម្លាំងហើយកម្លាំងគេត្រូវគ្នាគេដឹងគ្នា តែមេហើយនឹងមេ អញ្ចឹង ទៅក៏បែកផ្អើលទៅ នេះហ្នឹងក៏រត់ ។

ដានី ៖ ពីណាគេរត់?

យ៉េង ៖ សុន សេន តាម៉ុក តានួន ជា ក៏ទៅអស់ទៅ ស្រាប់តែបានប៉ុន្មានថ្ងៃស្រែកតាមវិទ្យុ ក្ដែងៗសុខភាព ចូលឃួនចូលអីណា ។

ដានី ៖ អញ្ចឹង?

យ៉េង ៖ បាទ!

ដានី ៖ បែកបាក់គ្នាហើយ?

យ៉េង ៖ បាទ!បែកបាក់គ្នាទឹមហ្នឹងម៉ោ

ដានី ៖ ចុះអ៊ំឈ្មោះ កំសត់ ដែលអ៊ំជួយហ្នឹង ម៉េចបានអ៊ំជួយ?

យ៉េង ៖ បើមនុស្សវាធ្លាប់រាប់អានគ្នា គេក៏ធ្លាប់ជួយព្យាបាលខ្ញុំឲ្យជាពីជំងឺ ហើយវាថារាប់អាន ខ្ញុំដូចជាបងប្អូនអញ្ចឹង ។

ដានី ៖ ឥឡូវគាត់នៅណា?

យ៉េង ៖ នៅអ៊ូតាពោរ ប៉ុន្តែមានផ្ទះមួយអាផ្ទះដែលអង្គការដាក់ធ្វើពេទ្យ វានៅគ្រប់គ្រងហ្នឹង ។

ដានី : បាទ!ចុះអ៊ំមានធ្លាប់ដូចបាយទឹក ម្ហូបអាហារអី ពេលរត់អីអ៊ំធ្លាប់ឲ្យអ្នកណាឬប្រជាជនអីឬក៏ប្រជាជន១៧មេសាអី អ៊ំមានដែលធ្លាប់ជួយគេដែរឬអត់ ឲ្យបាយឲ្យទឹក ឬប្រាប់ផ្លូវគេដែរ?

យ៉េង : បើកាលពីមុនខ្ញុំអត់មានទេ ព្រោះវាចេះមានតែដូចកាលគេជម្លៀសគេអីពីកម្ពាំងពីនោះប៉ុនអន្តភាពគេចាត់តាំងទៅ គេចាត់តាំងឲ្យដាំបាយដាំអីរៀបចំឲ្យប្រជាជនហូបអាហ្នឹង មានបើថាឲ្យនេះអាហ្នឹងអត់ទេខ្ញុំមិនដែល ។

ដានី : ចុះអ៊ំកាលមុនអ៊ំមានប្រសាសន៍មុនថាអ៊ំរត់ម៉ោដល់កំពង់ឆ្នាំងហើយដំណើរវាយ៉ាំងម៉េចទៅរហូតមកដល់ម៉ាខ្មែរនេះ?

យ៉េង : អាហ្នឹងបើនិយាយពីប្រវត្តិឡើងវិញវាដូចកំសត់ដែរ អ្នកស្រ្តីពោះធំ មានកូនខ្ចីអីឲ្យជិះឡានម៉ោ ហើយបើនារីៗយុវ៉ាន់អីគឺឲ្យដើរ ប៉ុនឥឡូវគេឲ្យស្នាក់ណា ឧទាហរណ៍ស្នាក់នៅគីឡូ១៣អញ្ចឹងគេឈប់នៅហ្នឹង យើងចេះតែដើរទៅ យប់ត្រង់ណាដេកត្រង់ហ្នឹង ទៅហូបតាមផ្លូវរហូតទៅយើងមានអង្ករ ចាន ឆ្នាំងស្ពាយតាមខ្លួនទៅ ចេះតែទៅៗ ចេះតែម៉ោមានជិះឡានខ្លះអីម៉ោ អាហ្នឹងសារក្រោយវិញហើយ ម៉ោដល់យើងបាត់ ដំបងនេះម៉ោដល់វ៉ារទេះភ្លើង ម៉ោដល់ហ្នឹងមានអាពួកនេះវាបោកក្រាប់បែកតាមរទេះភ្លើងត្រូវរបួសអាកូនក្មេង ហើយខ្ញុំក៏ចុះម៉ោតាមហ្នឹងម៉ោ ម៉ោតាមបវិលម៉ោ ។

ដានី : ហើយកាលហ្នឹងប្រពន្ធកូន អ៊ំ ម៉ោជាមួយអ៊ំដែរ?

យ៉េង : ម៉ោជាមួយគ្នា ម៉ោជួបគ្នានៅកំពង់ឆ្នាំង ហើយម៉ោជាមួយគ្នា ម៉ោអញ្ចឹងទៅដើររសាត់រសែងដើរ គិតតែម៉ោឆ្ងាយទៅអញ្ចឹង ដើរកាត់ទៅប៉ៃលិន ប៉ៃលិនឆ្ងាយទៅរហូតដល់បន្ទាយសំឡូត ទៅដេកបន្ទាយសឡូត ។

ដានី : គេហៅបន្ទាយអាឈ្មួនៗហ្នឹង?

យ៉េង : មិនមែនទេ!កាលនោះជំនាន់យាយឡូតហ្នឹងគាត់ជាអ្នកតស៊ូ មិនដឹងអ្នកណាជាអ្នកកាន់កាប់ទេ បន្ទាយហ្នឹង សម័យ៣ឆ្នាំយាយឡូតគេអ្នកតស៊ូ ។

ដានី : អ្ហ៊ូ!យាយឡូតគាត់អ្នកតស៊ូ?

យ៉េង : បាទ!កន្លែងបន្ទាយហ្នឹងគេហៅសំឡូត ដល់ទៅដល់ហ្នឹងទៅឈប់នៅហ្នឹង ឈប់នៅហ្នឹងបាន២-៣យប់ ទាល់ទីឡើងភ្នំហើយ ទៅនោះសារឡប់វិញៗ តាម៉ុក ដឹកឡានចូលចេះទៅតាមដង្ហែន ម៉ោបវិលវិញ ម៉ោបវិលធ្លាក់មកពិល៥ដើម ធ្លាក់ម៉ោកៀលម៉ោម៉ោយើងនេះម៉ោទំនប់ដាច់ម៉ក់ហើននេះ បានកៀលម៉ោចេះចូលទៅថៃរហូត ។

ដានី ៖ ចូលទៅថៃ?

យ៉េន ៖ បាទ!

ដានី ៖ ចូលទៅថៃចូលទៅកន្លែងណា?

យ៉េន ៖ កាលដែលពេលចូលៗនៅបឹងប៉េននេះ ដើរអញ្ចឹងទៅដើរតាម សុខ ដៃ ដើរតាមជាដូរព្រំដែន ទៅអញ្ចឹងទៅ ទៅនៅត្រាំង ដល់នៅត្រាំងហ្នឹងយូរដែរយួនវ៉ៃ យួនវ៉ៃបកមកវិញ បកម៉ោចក្រីៗវិញ ដល់នេះម៉ោៗចុះឡើងៗម៉ោនៅម៉ាឡៃហ្នឹង ។

ដានី ៖ កាលចូលទៅដីថៃចូលទៅយូរឬអត់ពេលដែលយួនវ៉ៃហើយ?

យ៉េន ៖ យើងទៅនៅដីថៃយូដែរ

ដានី ៖ គេហៅអីគេនៅកន្លែងថៃ?

យ៉េន ៖ កន្លែងថៃគេហៅ ឡែម

ដានី ៖ ទល់កន្លែងជិតឡែមហ្នឹងដែរ?

យ៉េន ៖ បាទ!

ដានី ៖ នៅហ្នឹងហើយបានបកចូលដីខ្មែរវិញ?

យ៉េន ៖ បាទ!ចូលដីខ្មែរវិញសារចុះសារឡើងមកនៅនេះ សារចុះសារឡើងមិនបកមកនៅនេះទៅនៅជំនុំតាង៉ុក ។

ដានី ៖ ជំនុំតាង៉ុកនៅណា?

យ៉េន ៖ អាហ្នឹងមិនទាន់កើតជំនុំតាង៉ុកទេ អាហ្នឹងក្រោយ មុនកើតជំនុំនេះគេហៅផ្សារ ក្បាល ដំរី នៅហ្នឹងមានអង្គការគេចុះម៉ោ ដឹកទៅនៅស្រះកែវ ។

ដានី ៖ អ៊ំទៅដែរ?

យ៉េន ៖ ខ្ញុំទៅដែរ ទៅនៅស្រះកែវបាន៨ខែ ដល់នេះគេរំសាយ អ្នកណាចង់ទៅជើងទៅៗ អ្នកណាចង់ម៉ោម៉ាឡៃនេះក៏ម៉ោៗ អ្នកណាចង់ទៅកោះកុងក៏ទៅៗ អ្នកណាចង់ម៉ោសាមគ្គីក៏ម៉ោៗ ខ្ញុំម៉ោម៉ាឡៃនេះវិញ ។

ដានី ៖ ម៉េចបានអ៊ំចង់ម៉ោម៉ាឡៃ?

យ៉េន ៖ វាចេះ អាហ្នឹងបើយើងប្រៀបធៀបៗទៅថានិន្នាការនយោបាយអប់រំ យើងជឿស៊ុប

ដានី ៖ ជឿស៊ុបម៉េចទៅអ៊ំ?

យ៉េន ៖ ជឿស៊ុបអារឿងពីការតស៊ូ មិនលះបង់ពីជីវរបស់ខ្លួន ខុះអីវាមានអ្នកទៅសហរដ្ឋទៅអីគេ ដែរ នោះកូនខ្ញុំនៅសហរដ្ឋcallមកលេងម្សិលមិញ កូនចិញ្ចឹម ។

ដានី ៖ អញ្ចឹងអ៊ំត្រឡប់មកដីខ្មែរវិញដោយសារយើងជឿស៊ុប?

យ៉េង ៖ បាទ!រដល់អញ្ចឹងគេថាអ្នកខ្លះគេថាឯងតែទៅវិញហ្នឹងគ្មានស៊ីស៊ីទេ ស៊ីគល់ព្រីង គល់ស្រឡៅ ខ្ញុំថាគល់អីក៏គល់ទៅយើងទៅដីយើងវិញ ពិបាកស្រណុកអីនៅដីយើង ។

ដានី ៖ កាលហ្នឹងពេលដែលរត់ចុះសារចុះសារឡើងពីណាគេជាអ្នកដឹកនាំកាលជំនាន់ហ្នឹង?

យ៉េង ៖ បើនិយាយទៅគេមានប្រធានអង្គភាព ប្រធានអង្គភាពហ្នឹងគេទទួលបទបញ្ជាពីលើមក ទៀតក៏យើងដើរទៅតាមគេទៅ គេឲ្យទៅត្រង់ណាទៅត្រង់ហ្នឹង ។

ដានី ៖ កាលហ្នឹងអ៊ំប្រធានអង្គភាពអ៊ំពីណាគេ?

យ៉េង ៖ មិត្តសម

ដានី ៖ ចុះអ៊ំៗលើៗគាត់មកទាក់ទងយើងដែរ?

យ៉េង ៖ អាហ្នឹងគឺទាក់ទង

ដានី ៖ គាត់នៅណាកាលហ្នឹង?

យ៉េង ៖ កាលហ្នឹងបើតាមគេឲ្យដឹង គាត់នៅសំឡូត ។

ដានី ៖ អ៊ំណាខ្លះនៅសំឡូត?

យ៉េង ៖ មិនដឹងអ៊ំណាខ្លះ តែថាតាៗនៅសំឡូត

ដានី ៖ ប៉ុន្តែអ៊ំអត់បានជួបគាត់ទេ?

យ៉េង ៖ អត់ទេ ខ្ញុំមិនដែលជួបគាត់

ដានី ៖ នៅពេលអ៊ំមកដល់សំឡូតដំបូងអ៊ំអត់ដែលជួបគាត់ទេ?

យ៉េង ៖ អត់ដែល នៅឆ្ងាយពីគ្នា

ដានី ៖ អញ្ចឹងពេលអ៊ំទៅកន្លែងតាង៉ុកបាន៨ខែ ហើយមកវិញម៉ោម៉ាឡៃវិញបានជួបគាត់ដែរឬអត់?

យ៉េង ៖ អត់ជួប ជួបតែត្រឹមគេហៅថាគណៈតំបន់ ។

ដានី ៖ ពីណាគេគណៈតំបន់?

យ៉េង ៖ គណៈតំបន់កាលមុនឥឡូវគាត់ឈប់ នៅកំពង់ឆ្នាំង

ដានី ៖ ពីណាគេ?

យ៉េង ៖ ឈ្មោះ លី

ដានី ៖ ឥឡូវគាត់ទៅនៅកំពង់ឆ្នាំងវិញ?

យ៉េង ៖ បាទ!ព្រោះគាត់ឈប់ធ្វើការងាររអីអស់ហើយ ។

ដានី ៖ អញ្ចឹងអ៊ំចូលមកម៉ាឡៃវិញឆ្នាំណា ខែ៧ មករា ៧៩ យើងត្រឡប់មកនេះវិញ?

យ៉េង ៖ បាទ!ខ្ញុំទៅ៧៩ ខែដើមឆ្នាំភ្លៀងអញ្ចឹង ម៉ោត្រឡប់វិញ ត្រឡប់ពីនោះវិញភ្លៀង

ដានី ៖ ឆ្នាំ៨០ឬក៏ឆ្នាំណា?

យ៉េង ៖ បែបខ្ទង់៨០ហើយ បើពីនោះវិញភ្លៀង ម៉ោភ្លៀងអើភ្លៀងតាមផ្លូវ ។

ដានី ៖ នៅពេលដែលអ៊ំមកនៅដំបូងម៉ាឡៃយើង មានសភាពយ៉ាងម៉េចទៅ?

យ៉េង ៖ មកនៅដំបូងនៅនេះសុទ្ធតែព្រៃទាំងអស់ មានតែផ្លូវដើងដើរទេ ។

ដានី ៖ កាលហ្នឹងគេហៅម៉ាឡៃតាំងពីមុនហ្នឹងម៉ោ ឬក៏គេអត់ហៅទេ?

យ៉េង ៖ អាហ្នឹងគឺថាពីដើមម៉ោ ក៏ខ្ញុំមិនដឹង ក៏ប៉ុន្តែមកដល់ប្រវត្តិយោធាគេធ្លាប់នៅហ្នឹង គេថាម៉ាឡៃៗ ។

ដានី ៖ មកដល់គេហៅម៉ាឡៃៗយើងហៅម៉ាឡៃតាមគេទៅ?

យ៉េង ៖ បាទ!

ដានី ៖ អញ្ចឹងម៉ាឡៃមានមុនយើងមកដល់ទៀត?

យ៉េង ៖ បាទ!គេថាភ្នំម៉ាឡៃ ប៉ុនខ្ញុំមកនៅនេះប៉ុន្មាន តាំងពី៧៩រហូតមកទល់ថ្ងៃនេះ ខ្ញុំរកភ្នំ ម៉ាឡៃមិនដឹងថាណាមួយជាភ្នំម៉ាឡៃទេ ។

ដានី ៖ អត់ដឹងថាភ្នំមួយណាភ្នំម៉ាឡៃ?

យ៉េង ៖ បាទ!ប៉ុនគេថាភ្នំម៉ាឡៃខាងក្នុងនោះ ហើយខ្ញុំមិនសូវជាអ្នកដឹងទេ បើពួកយោធាប៉ុនគេដឹង ។

ដានី ៖ អញ្ចឹងមកដល់ដំបូងសុទ្ធតែព្រៃ?

យ៉េង ៖ បាទ!សុទ្ធតែព្រៃទាំងអស់ តាំងពីមាត់ទន្លេ

ដានី ៖ ព្រៃអីខ្លះទៅ ព្រៃហ្នឹង?

យ៉េង ៖ ព្រៃហ្នឹងវាមានតាំងពីដើមសង្កែ ដើមស្រឡៅ តាំងពីឈើទាល ខ្លះប៉ុនដើមឈើធំៗវារវើលទេណា!

ដានី ៖ បាទ!ដើមឈើធំៗប៉ុណ្ណាទៅ?

យ៉េង ៖ ប៉ុនៗពាងនោះ បាទ!ដើមស្ពង់ធំៗដែរ ចង់ប៉ុនៗពាងនោះ ប៉ុនធំតែដើមហ្នឹងទេ ធំ ដាងគេ

ដានី ៖ នៅពេញហ្នឹង?

យ៉េង ៖ បាទៗ!តាមហ្នឹង ត្រង់ហ្នឹងជ្រុងស្រឡៅ ត្រង់នោះជ្រុងដើមស្រង្កែ

ដានី ៖ អាដើមឈើហ្នឹងវាដុះមួយដុំៗ តាម?

យ៉េង ៖ ចំរុះគ្នា អាណាអានេះខ្លាំងទៅវាច្រើន វាច្រើនសុទ្ធតែដើមស្រឡៅ ត្រង់នេះត្រង់មុំផ្ទះខ្ញុំនេះសុទ្ធតែដើមមានបន្លា ដែវាប៉ុនៗម្រាមដៃហើយល្វីង ហ្នឹងហៅដូចរកឈ្មោះវាមិនឃើញទេ ហើយខាងក្រោយនេះឡើងពីអូរនេះទៅសុទ្ធតែអាស្វិៗពេញទាំងអស់ ។

ដានី ៖ អញ្ចឹងសុទ្ធតែឫស្សីអញ្ចឹងដល់ពេលធ្វើផ្ទះម៉េចទៅ?

យ៉េង ៖ កាលពីមុន អានេះផ្លូវដើរដើម កាលពីមុននៅខាងមុខនោះទេ ធ្វើផ្ទះនៅអូរនោះនៅក្បែរមាត់អូរនោះ ។

ដានី ៖ ធ្វើផ្ទះម៉េច ផ្ទះធំៗឬតូចៗ?

យ៉េង ៖ ផ្ទះវាកាលដែលនៅមុនដំបូងគ្រាន់តែធ្វើរោងនៅបណ្តោះជ្រកនៅអាសិនណា៎!

ដានី ៖ បាទ!

យ៉េង ៖ ដល់ក្រោយមកក៏កាប់ឈើដើមប៉ុនៗនេះធំយកទៅធ្វើសសរទៅ ប៉ុនៗសសរផ្ទះខ្ញុំហ្នឹងក៏ធ្វើធំៗប៉ុនៗផ្ទះខ្ញុំទៅ ប្រកស្បូវទៅ ។

ដានី ៖ តូចៗប៉ុនៗហ្នឹងដែរ?

យ៉េង ៖ បាទ!

ដានី ៖ អញ្ចឹងដូចថាពេលដែលយើងម៉ោដំបូង យើងម៉េចាប់ឬក៏យើងដាក់ឈ្មោះភូមិ ឃុំអីដូចឥឡូវទេ ដូចឥឡូវយើងមានភូមិច្រើន ដូចមានភូមិបឹងប៉េង មានភូមិសង្កែ ភូមិចំបក់ ភូមិអីហើយនៅខាងម៉ាខ្សែនោះមានភូមិកណ្តាល ភូមិថ្មី ភូមិដូងអីហូរហែរ ដូចថាអឹមានប្រសាសន៍ម៉េចថាសុទ្ធតែព្រៃ អញ្ចឹងយ៉ាងម៉េចទៅ?

យ៉េង ៖ វាមាន ដល់ក្រោយម៉ោ គឺថាយើងបែកយកកម្ចាំងពី យើងមកនៅនេះយកកម្ចាំងពីនេះម៉ោកោះកុងម៉ោ កម្ចាំងពីដងរែកម៉ោ ភូមិនេះវាមានភូមិចំការចេក ភូមិបឹងត្រកួនវាមានអញ្ចឹងវាមានដែរ នោះដូងអញ្ចឹងទៅ ឯនោះទៅភូមិចំបក់ទៅ វាមានអូរស្រឡៅនោះទៅ ដល់យើងក្រោយម៉ោវាមានសមាហរណកម្មអញ្ចឹហទៅវាប្រែថ្មី អានេះវាទៅជាភូមិសង្កែវិញ ហើយនោះហៅភ្នំរូង ទៅពីភ្នំរូងទៅ ទៅភូមិជ្រៃ ភូមិល្វា ភូមិបឹងប៉េងអីអញ្ចឹងទៅ ។

ដានី ៖ បាទ!ប្រជាគេដាក់តាមឈ្មោះដើមឈើហើយ?

យ៉េង ៖ បាទៗ!

ដានី ៖ ចុះអ៊ឹកាលពីចូលមកនៅដំបូងដូចថា ការរស់នៅ ការហូបចុក ការតស៊ូអីយ៉ាងម៉េចដែរពេលម៉ោដំបូង?

យ៉េង ៖ ម៉ោងដំបូង អាហ្នឹងគឺថាបើការហូបចុកវាអត់មានពិបាកអីទេ បានថាអត់មានពិបាកម៉េច ពិបាកៗចេះដែរ ពិបាកត្រង់ថាពូៗគេអត់ឲ្យមានរបបអង្ករទេ ។

ដានី ៖ អង្ករយ៉ាងម៉េចទៅ?

យ៉េង ៖ របបអង្ករ អង្ករគេជួយៗតែមនុស្សស្រីទេ យោធាគឺដាច់ខាតអត់មានទេ ប៉ុន្តែ យើងធ្វើម៉េច យើងថាធម្មតាគេថាត្រីឆៀតឆៀតពង យើងថានយោបាយ អញ្ចឹងស្រី ដូចយាយខ្ញុំអញ្ចឹង យក១០ដើង ២០ដើងអីយកទៅឲ្យតែយកបាន ចុះដឹកម៉ោ១ម្តង មាន១០-២០កាំម៉ាសនោះ ។

ដានី ៖ បាទ!

យ៉េង ៖ មានអង្ករ ត្រីខ ខ្លាញ់

ដានី ៖ អញ្ចឹងបានន័យថាកាលហ្នឹងអង្ករគេជួយតែស្ត្រី តែកុមារ តែដោយសារយើងរស់ នៅក្នុងគ្រួសារជាមួយអញ្ចឹង ដល់ពេលគាត់យកម៉ោ យើងហូបចុកអីជាមួយគ្នាទៅ?

យ៉េង ៖ បាទ!ព្រោះអញ្ចឹងគឺថារដ្ឋជញ្ជូនម៉ោដាក់ឃ្លាំង យើងជញ្ជូនម៉ោឲ្យបានច្រើនដាក់ឃ្លាំង កាលណាអស់ យើងទៅបើយកមកហូបវិញ ប៉ុនយើងបំរើការវេន អ្នកណាទៅមុខៗ អ្នកណាទៅក្រោយៗទៅ ។

ដានី ៖ បាទ!កាលហ្នឹងយើងរៀបចំយ៉ាងម៉េចទៅ ដូចថាអ្នកណាត្រូវនៅមុខ អ្នកណាត្រូវនៅ ក្រោយ ដូចថាអ្នកទៅមុខខាងសរមភូមិអញ្ចឹង ហើយអ្នកនៅក្រោយយើងត្រូវធ្វើ អីខ្លះ?

យ៉េង ៖ អកនៅក្រោយនេះ អ្នកណាបិទជ្រលងបិទជ្រលងទៅ អ្នកណាទៅចាក់ជ្រលងទៅចាក់ ជ្រលងទៅ គេហៅថាបុរាណ រួមផ្សំទាំងសម័យ ។

ដានី ៖ បាទ!បើអ្នកនៅខាងមុខគេវៃ គេវៃរាល់ថ្ងៃឬយ៉ាងម៉េច?

យ៉េង ៖ វាមិនរាល់ថ្ងៃទេ វាមានថ្ងៃណាក៏ទៅវៃទៅ ថ្ងៃណាក៏ទៅឆ្មក់ទៅ ថ្ងៃណាដឹងតែម៉ោទៅ យើងឡើងកាត់ផ្លូវទៅ ។

ដានី ៖ ចុះអ៊ំៗគាត់ម៉ោនៅហ្នឹងជាមួយយើងដែរឬអត់ទេ?

យ៉េង ៖ អូរអត់ទេ!យូរៗឃើញគាត់ម៉ោម្តង ម៉ោហ្នឹងយើងទៅរកនៅផ្ទះមិនដែលបានទៅឃើញ មុខទេ អ៊ំៗមិនដែលអ្នកណាទៅឃើញមុខទេ ។

ដានី ៖ ចុះអ៊ំ អៀង សារី ?

យ៉េង ៖ បើអ៊ំ អៀង សារី ក្រោយម៉ោគាត់ម៉ោនៅជាប់ គេហៅមន្ទីរក្នុងកន្លែង ដល់ក្រោយ ម៉ោយើងម៉ោទទួលសាលតាំងមកទទួលសម្តេច ។

ដានី ៖ សម្តេចយាន់ម៉ៅ?

យ៉េន ៖ បាទ!សម្តេចយាន់ម៉ៅ ទៅទទួលសាលតាំងនៅកន្លែងហ្នឹង បានឥឡូវកន្លែងហ្នឹង គេធ្វើកន្លែងហ្នឹងអត់ឲ្យបាត់ ។

ដានី ៖ អ៊ំ អៀង សារី គាត់នៅហ្នឹង?

យ៉េន ៖ បាទ!គាត់នៅក្រៅផង គាត់នៅហ្នឹងផង

ដានី ៖ គាត់មានផ្ទះមានអីគាត់នៅហ្នឹង?

យ៉េន ៖ បាទ!មានផ្ទះរបស់គាត់ ។

ដានី ៖ តែអ៊ំ អៀង សារីទេ អ៊ំ ផ្សេងទៀតអត់មានទេ?

យ៉េន ៖ អត់មានទេ គាត់គ្រាន់តែម៉ៅម្តងម្កាលគាត់ជួបគ្នាគាត់ទេ យើងតូចតាចអត់បានទៅជិតទេ ។

ដានី ៖ ចុះកាលដែលអ៊ំមកនៅម៉ាឡៃដំបូងអ៊ំទទួលខាងអីទៅ?

យ៉េន ៖ ខ្ញុំកាលមកនៅដំបូងអត់មានអីទេ ជាប្រជាជនសាមញ្ញ ដល់ក្រោយខ្ញុំគេហៅទទួលគ្រប់គ្រងប្រជាជនតាមភូមិ បើនិយាយទៅគេហៅប្រធានភូមិ ក្រោយម៉ោក៏គេហៅថា ឃុំ ភូមិហ្នឹងក៏នៅគ្រប់គ្រងប្រជាជនទៅ មើលការខុះខាតមើលអីៗទៅ ដឹកនាំទៅ បើខុះខាតអីទៅយកសេចក្តីរាយការណ៍ពីប្រជាជនហ្នឹងទៅធ្វើការប្រជុំខាងលើទៅក៏ ដើម្បីដោះស្រាយការខុះខាតអញ្ចឹងទៅ ។

ដានី ៖ បាទ!អញ្ចឹងអ៊ំមុនគ្រប់គ្រងភូមិ ភូមិហើយឃុំ?

យ៉េន ៖ បាទ!

ដានី ៖ ពីឆ្នាំណាម៉ៅអ៊ំចាប់ផ្តើមគ្រប់គ្រងភូមិ?

យ៉េន ៖ វាភ្លេចឆ្នាំហ្នឹង មើល៉ខ្ញុំម៉ៅធ្វើនេះបាន២ឆ្នាំ ឆ្នាំប៉ុន្មានទេ ដែលឲ្យប្រជាជនបង្កើតក្រុម ហ៊ុនឲ្យរកស៊ីដើម្បីចែកគ្នា ។

ដានី ៖ មុនផ្តាច់ខ្លួន?

យ៉េន ៖ មុនៗ អាហ្នឹងមុនដករទេះគោហ្នឹងទៀត ។

ដានី ៖ អ្ហូ!មុនដករទេះគោហ្នឹងទៀត

យ៉េន ៖ មុនហ្នឹង បង្កើតឲ្យមានទិញម៉ាស៊ីនអាលឈើ ក្រុមហ៊ុនចែក អ្នកណាគេទៅមុខក៏ទៅមុខ ទៅ អ្នកណាដែលនៅក្រោយឲ្យរកទៅដើម្បីជួយគ្នា ។

ដានី ៖ កាលហ្នឹងអ៊ំភូមិអីគេ គេហៅភូមិអី?

យ៉េង ៖	អាហ្នឹងគេហៅទួលធ្នូរ ពីដើមគេហៅវត្តទួលធ្នូរ

ដានី ៖	នៅក្នុងឃុំអីគេ?

យ៉េង ៖	អាហ្នឹងបើយើងនិយាយទៅគេអត់ទាន់មានដាក់ឈ្មោះឃុំទេ ហៅតែភូមិនៅទួលគ្រប់គ្រងទាំងអស់តែម្តង ព្រោះនៅក្នុងតំបន់គ្រប់គ្រងទាំងអស់ ព្រោះនៅក្រោមការក្តោបក្តាប់យោធាទាំងអស់ រដ្ឋអំណាចយោធាទាំងអស់ ។

ដានី ៖	បាទ!

យ៉េង ៖	ដល់អញ្ចឹង ដល់ក្រោយម៉ោគេបង្កើតអាហ្នឹងវាកើតរឿងរ៉ាវ ខ្ញុំនេះគឺខាងទទួលសេដ្ឋកិច្ចទទួលសេដ្ឋកិច្ចហ្នឹងគឺថាខាងលើត្រូវការអី អត់មានទៅទាក់ទងម៉ោប្រធាននយោបាយគ្រប់គ្រងទេ មកទាក់ទងសេដ្ឋកិច្ចនេះចំតែម្តង ដល់អញ្ចឹងគឺថាវាមានប្រទូសសរាយថា ខ្ញុំនេះវាអត់គិតការងារជួយដឹកនាំប្រជាជនអី គិតតែពីរឿងរកស៊ីផ្ទាល់ខ្លួន ក៏ខ្ញុំរាយ ការណ៍ប្រាប់សុខ ភាពទៅ សុខ ភាព គាត់ថាចេះអត់ឲ្យឈប់ទេ ខ្ញុំថាបើភាពឯងឲ្យខ្ញុំឈប់ក៏ខ្ញុំឈប់ មិនឲ្យឈប់ក៏ខ្ញុំឈប់ដែល ព្រោះធ្វើទៅៗវាអត់ត្រូវគ្នា ធ្វើការងារវាអត់ស៊ីសង្វាក់គ្នាអញ្ចឹងឲ្យធ្វើអីកើត ម្នាក់លិចម្នាក់កើត បើវាអត់ឯកភាពគ្នាអញ្ចឹងប្រណែននិន្ទាថាខ្ញុំនេះរកស៊ីដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ខ្ញុំនេះអត់មានបានផលប្រយោជន៍ផ្ទាល់ខ្លួនអីទេ ព្រោះផលប្រយោជន៍នេះ ផលប្រយោជន៍រួម ដើម្បីរួមទាំងអស់ ខាលើឲ្យធ្វើទេ មិនមែនខ្ញុំជាអ្នកធ្វើខ្លួនឯងទេ ដល់អញ្ចឹងទៅខ្ញុំក៏ឈប់ ម៉ោជាប្រជាជនដល់សព្វថ្ងៃនេះទៅ ។

ដានី ៖	បាទ!

យ៉េង ៖	បាទ!មានតែប៉ុណ្ណឹង

ដានី ៖	អញ្ចឹងកាលហ្នឹង តាហុង គាត់ខាងនយោបាយខាងអីដែរ

យ៉េង ៖	តាហុងក្រោយម៉ោគាត់ទៅនៅជើងនោះ ទៅនៅ៥១៩នោះទៅនៅខាងជើងនោះ

ដានី ៖	ខាងណាទៅ?

យ៉េង ៖	ខាងដងរែកនោះ កាលពីមុនគាត់នៅគ្រប់គ្រងនៅនេះ ដល់ក្រោយម៉ោគាត់ទៅនៅជើងនោះវិញ ។

ដានី ៖	គាត់ទុកឲ្យតាភាពគ្រប់គ្រងវិញ?

យ៉េង ៖	បាទ!អាហ្នឹងមានកម្លាំងបែកទៅខាងជើងផង នៅនេះផង ។

ដានី ៖	ម៉ុំណាទៅខាងដងរែក?

យ៉េង ៖ វាខ្ញុំស្គាល់វាមិនច្បាស់អស់ទេ ម៉ាជួរភ្នំដងរែកហ្នឹងរហូតទៅខត្តរ ។

ដានី ៖ ចុះអ៊ីដល់ពេលឆ្នាំប៉ុន្មាន ពុថាឆ្នាំ៨៥យួនខាងរដ្ឋកម្ពុជាវៃបុកចូលមកដល់យើងហ្នឹង?

យ៉េង ៖ បាទ!ចូលម៉ោឥឡូវគ្រាន់តែមីនយួន ហើយខ្មែរយើងចូលដាក់ពីអូរក្រោយផ្ទះខ្ញុំទៅដល់មាត់អូរ១៥ខ្សែ ហើយរបងបង្គោលដែកអាបង្គោលជ្រុងនេះ នៅចំងាយពីមាត់អូរប្រហែលជាកន្លែងខ្លះ២០ម៉ែត កន្លែងខ្លះក៏វាជាង១០០ម៉ែត តាមជិតតាមឆ្ងាយអូរវា

ដានី ៖ ចុះពេលដែលយួនចូលមកដល់ហ្នឹង តើប្រជាជនទៅនៅណាទៅ?

យ៉េង ៖ គ្រាន់តែយួនចូលម៉ោ យើងដឹងថាកម្លាំងយើងទប់មិនគ្រប់ហើយ វាចេះកាលពីមុនគឺថាយើងដឹង ធម្មតាអារឿងបញ្ហាហ្នឹងវាមានផ្ទៃក្នុង គេៗមានផ្ទៃក្នុង យើង យើងៗមានផ្ទៃក្នុងគេ អញ្ចឹងគឺយួនត្រូវបុកម៉ោ ឥឡូវដូចថាមេហៅប្រជុំប្រាប់ ដូចថាយើងត្រូវត្រៀមលក្ខណៈ ដល់ថ្ងៃយួនវាបុកម៉ោៗ វាផ្ទោងចេញពីម៉ោៗវាធ្លាក់នោះ កាលនោះវាមានគេលេហ្ទុនខ្សែយើងហ្នឹងសម្រាប់ទាក់ទង ដល់ទាក់ទងទៅគេថា ឥឡូវសភាពការណ៍មិនស្រួលហើយ ត្រូវដកកម្លាំងប្រជាជនចេញ ខាងលើថាចាំមើលសិនមើស៎ កុំអាល មានចាំមើលខាងលើណា៎ ឥឡូវសភាពការណ៍មកដល់ហើយឥឡូវដកកម្លាំងចេញ ទៅដកចេញទៅនៅដីថៃ ព្រោះយើងទាក់ទងជាមួយថៃហើយ ។

ដានី ៖ ទៅនៅគេហៅអីគេ?

យ៉េង ៖ ទៅនៅគេហៅថាភ្នំតាងោល ចំពីមុខផ្ទះខ្ញុំហ្នឹងទៅគេហៅភ្នំតាងោល ដល់ហើយបានដឹកយកទៅដាក់នៅតាង៉ុកនេះ កើតជំរុំតាង៉ុកហ្នឹងក្រោយអាពីមុខនោះគ្រាន់តែស្នាក់នៅហើយទៅ

ដានី ៖ កន្លែងគេថាទៅ៨៥ហ្នឹង?

យ៉េង ៖ បាទ!អាហ្នឹងនៅ៨៥មួយចំនួន ទៅនៅភ្នំតាង៉ុកមួយចំនួន ៨៥គឺនៅតែកម្លាំងប្រព័ន្ធយោធាទេ ហើយប្រជាជនសុទ្ធទៅនៅនោះម៉ង ។

ដានី ៖ ចុះអ៊ំនៅណាកាលហ្នឹង?

យ៉េង ៖ ខ្ញុំទៅនៅតាង៉ុក

ដានី ៖ អ៊ំទៅនៅយូរទេនៅតាង៉ុក?

យ៉េង ៖ ខ្ញុំទៅបាន៨ខែ

ដានី ៖ ចុះប្រពន្ធកូន?

យ៉េង ៖ ប្រពន្ធកូនទៅនៅនោះទាំងអស់

ដានី ៖ ទៅនៅនោះទាំងអស់ ប៉ុន្តែអ៊ំទៅនៅបាន៨ខែ អ៊ំមកវិញ?

យ៉េង ៖ បាទ!ម៉ោទាំងអស់គ្នាវិញ

ដានី ៖ ម៉ោណាវិញ?

យ៉េង ៖ ម៉ោនៅ៨៥

ដានី ៖ ទៅនៅគាង៉ុកហ្នឹងម៉េចទៅបានម៉ោវិញ?

យ៉េង ៖ ខាងប្រធានជុំហ្នឹងគេដកឲ្យខ្ញុំម៉ោ ឲ្យខ្ញុំម៉ោជួយដឹកនាំប្រជាជននៅនេះ ម៉ោដល់ទៅមានគេដឹកនាំហើយទៅខ្ញុំទៅជាប្រជាជនធម្មតា ។

ដានី ៖ អ៊ំម៉ោនៅ៨៥បានយូរដែរ?

យ៉េង ៖ បាទ!ម៉ោនៅយូរដែរ ៨៩-៩០យើងចូលម៉ោនៅដីនេះ

ដានី ៖ ដល់ពេលចូលមកវិញសុទ្ធតែមីន?

យ៉េង ៖ ម៉ោវិញសុទ្ធតែមីន ចេញទៅ២ឆ្នាំ អាដីវាលហ្នឹងដើមឈើប៉ុនៗនេះហើយ

ដានី ៖ ដើមឈើដុះវិញ?

យ៉េង ៖ ដុះវិញប៉ុនៗហ្នឹង ដីនេះកាប់វាលាភ្លឺងទាំងអស់ ដល់ពេលម៉ោវិញ អាខ្លះប៉ុនដើមគាង៉ុក

ដានី ៖ ដល់ពេលយើងម៉ោវិញយួននៅខាងទ័ព?

យ៉េង ៖ អាហឹងយើងវៃបានទៅ យើងវៃដណ្តើមយកដីហ្នឹងបានវិញ នេះភ្នំនេះសុទ្ធតែវាជីកវាជីកដីរាបខ្ទង ។

ដានី ៖ វាជីកធ្វើអីវា?

យ៉េង ៖ អាហ្នឹងបើតាមពាក្យចចាមរាមគេថា ជំនួយការសូវៀត កន្លែងនៅ ហើយវាចាក់ថ្មប៉ុនៗនេះ ប្រហែល២តឹក ចាក់ហើយវាមានប្រដាប់គេសក ដូចប៉ុនៗហ្នឹហហើយ ជីកថែមទៀតទៅ ក្នុងរោងភ្នំ ហើយគេធ្វើដណ្តើរដែក ចំចុះពីលើទៅ ប៉ុនខ្មោច សុន សេនឲ្យយកម៉ាសេកម៉ោទិចចោល ។

ដានី ៖ កំទិចចោលទៅ?

យ៉េង ៖ បាទ!

ដានី ៖ ម៉េចបានគាត់ឲ្យកំទិចចោល?

យ៉េង ៖ មិនដឹង

ដានី ៖ ព្រោះគេចេញទៅបាត់អស់ហើយយើងទុកទៅ?

យ៉េង ៖ អាហ្នឹង បើតាមគំរោងការហ្នឹងគេចង់ទុកឲ្យ គេហៅថាសម្រាប់ទេសចរណ៍ សភាព ការណ៍លក្ខណៈសង្គ្រាមម៉េច

ដានី ៖ បាទ!

យ៉េង ៖ ប៉ុនមិនដឹងគាត់យកមកម៉េច គាត់ឲ្យកំទិចចោលទៅ យើងមិនដឹង

ដានី ៖ សុន សេន គាត់ជាអ្នកគ្រប់គ្រងនៅហ្នឹងដែរ?

យ៉េង ៖ បាទ!

ដានី ៖ ក្រែងថាអ៊ំ អៀត សារី ?

យ៉េង ៖ អេ៎! អៀង សារី តូចជាង សុន សេនទេ ព្រោះគាត់កាន់យោធា

ដានី ៖ ប៉ុនដល់ពេលយើងមកវិញឆ្នាំ៨៩-៩០ហ្នឹងយ៉ាងម៉េចដែរ ស្ថានភាពពេលដែលកងទ័ព ដកម៉ោអីមានប្រសាសន៍ម៉េចថាមានមីន១៥ខ្សែ

យ៉េង ៖ បាទ!

ដានី ៖ អាហ្នឹងយើងដោះចេញសិន ចាំយើងមកនៅ?

យ៉េង ៖ អត់ទេ!អ្នកណាម៉ោនៅ ចាប់ទៅដោះទៅ ដើរមើលដើរដោះទៅ យើងស្គាល់ហើយដូច លោកអញ្ជឹងធ្លាប់ដោះទៅ វាមកដោះមកអីឲ្យទៅ ។

ដានី ៖ បាទ!ចុះយើងម៉េចមិនទៅនៅដីថៃទៀត ព្រោះដីយើងសុទ្ធតែមីនអញ្ជឹង?

យ៉េង ៖ ព្រោះយើងរំដោះបានហើយ ម៉េចទៅដីគេទៀត ត្រូវតែនៅដីយើង ហើយយើងទៅ រុករានទៅ បង្កបង្កើនផលទៀតតាមហ្នឹងទៅ អង្ករដាំដុះ ចេក អំពៅអី ពោត ។

ដានី ៖ បាទ!អញ្ជឹងពេលដែលយើងមកវិញយើងបង្កបង្កើនផលខ្លួនយើងហើយ?

យ៉េង ៖ បាទ!ពោតកាលម៉ាជំនាន់នោះ វា១គីឡូបានតែ២បាត ១បាតកន្លះ

ដានី ៖ ប៉ុន្តែយើងដាំបានច្រើន?

យ៉េង ៖ បានវាមិនបានច្រើនអីទេ បាន៧-៨បាវ ៨-១០បាវម្នាក់អញ្ជឹង ហើយក្រោយម៉ោ បាន២០-៣០បាវអី ព្រោះយើងធ្វើតាមកម្លាំង បើមានកម្លាំងច្រើនទៅក៏បាន៥០-៦០បាវ

ដានី ៖ យើងយកទៅលក់ឲ្យថៃទៅ?

យ៉េង ៖ លក់ឲ្យថៃ ថៃមកទិញដល់មាត់អូរនេះ ហើយយើងនេះទៅក៏ធ្វើស្រូវធ្វើអីទៅ ជួនកាល ក៏ធ្វើបាន៧-៨បាវ ៨-១០បាវអញ្ជឹងទៅ លក់ឲ្យថៃ ។

ដានី ៖ ចុះមានគ្រោះថ្នាក់អីច្រើនទេ ដល់ពេលយើងមកនៅក្រោយនេះ?

យ៉េង ៈ វាអារឿងគ្រោះថ្នាក់វាមានច្រើនដែរ វាមានរឿងថាការហាមប្រាមហើយ ប៉ុន្តែអ្នកខ្លះគេហៅថាវាសេចក្ដីលោភលន់ចង់បាន ដើរទៅមិនបានប្រយ័តជាន់មីន ដាច់ជើង

ដានី ៈ ច្រើនដែរ?

យ៉េង ៈ បាទ!មេឃុំនោះជាន់មីនដាច់ជើងដែរ

ដានី ៈ គាត់ជាន់មីន?

យ៉េង ៈ បាទ!ជាន់មីន

ដានី ៈ ចុះអ៊ឹះអ៊ើ!អញ្ចឹងពូថាស្រុក ភូមិហ្នឹងចាប់ផ្ដើមកកើតតាំងពីយើងត្រឡប់មកវិញឆ្នាំ៨៩-៩០ហ្នឹងចាប់ផ្ដើមបង្កបង្កើនផល មានភូមិ មានស្រុក មានផ្ទះធំៗចាប់ពីពេលហ្នឹងម៉ោ ឬក៏ក្រោយមកទៀត?

យ៉េង ៈ បាទ!អាហ្នឹងផ្ទះកាលពីនោះ ពេលដែលយើងត្រលប់មកវិញផ្ទះនៅតូចៗទេ ផ្ទះដែលកកើតធំ ក្រោយពីសមាហរណកម្មហើយ កាលពីមុនវាមិនមានផ្ទះធំៗអញ្ចឹងទេ ផ្ទះឈើដែរក៏ប៉ុនថាផ្ទះល្មមៗ ក្រោយហ្នឹងម៉ោ៣-៤ឆ្នាំម៉ោផ្ទះហ្នឹងកាន់តែ ចេះតែរីក ឡើងៗ

ដានី ៈ ចុះយ៉ាងម៉េច ចាប់ផ្ដើមយើងធ្វើខ្លួនឯង ដីធ្លី ផ្ទះសម្បែងខ្លួនឯង ចាប់ពីសមាហរណកម្មហ្នឹងម៉ោ ឬពីមុនហ្នឹងទៀត?

យ៉េង ៈ បាទ!ពីមុនហ្នឹងម៉ោក៏យើងធ្វើខ្លួនយើងដែរ អត់មានអ្នកណាធ្វើនេះទេ ប៉ុនគ្រាន់តែថាផ្ទះវាតូច

ដានី ៈ បាទ!ប៉ុន្តែកាលហ្នឹងយើងនៅមានរបបមានអី?

យ៉េង ៈ កាលដែលពីមុនយើងនៅមានរបប ហើយដល់ក្រោយម៉ោគឺប្រជាជនលែងមានរបប ហើយអត់មានរបបទេ រកដោយខ្លួនឯងម៉ង

ដានី ៈ បាទ!ចាប់ពីពេលណាម៉ោ?

យ៉េង ៈ ឥឡូវនិយាយផ្ដាច់ សមាហរណកម្មលែងមានអីហើយអស់ហើយ

ដានី ៈ ចុះដូចថាដីផ្ទះ ដីស្រែ ដីចំការ គេចែកឲ្យឬក៏យើងចាប់ដោយខ្លួនយើង?

យ៉េង ៈ ដីនេះបើតាមការពិតទៅ គឺថាកាលពីដើមគេថាឥឡូវនោះ ម៉ាកងនេះ ម៉ាក្រុមនេះទៅនៅមួយដុំនេះអញ្ចឹងទៅ យើងចាប់តូចៗទៅ ប៉ុនដល់ពេលក្រោយម៉ោ ដូចថារត់ទៅនៅដីថៃប៉ុន្មានដែលឃួនបុកវៃចូល ហើយមីនជាង១០ខែហ្នឹង ម៉ោវិញគឺថាចាប់យកខ្លួនឯង ហើយខ្ញុំអារឿងដីដែលចែកចាយហ្នឹងគឺថាអត់បានទេ មានតែដីយោធាទេចាប់យកខ្លួនឯង ។

ដានី : ចុះដីចំការដូចថាគ្រួសារមួយៗចាប់យកខ្លួនឯងឬក៏យ៉ាងម៉េច?

យ៉េង : វាចេះ កាលពីមុនវាមានដែរ មានដីចំការគេចែកឲ្យ

ដានី : អញ្ចឹងអ៊ំ ពេលណាបានអ៊ំទៅលេងស្រុកកំណើត?

យ៉េង : បាទ!អាហ្នឹងគឺថាយើងសមាហរណកម្មហើយ បានទៅ

ដានី : សមាហរណកម្មឆ្នាំ៩៦ហើយ?

យ៉េង : បាទ!

ដានី : អ៊ំបែកពីផ្ទះម៉ោយូរទេ?

យ៉េង : បាទ!បើនិយាយពីបែក បើឥឡូវគឺថា ៧៥ខ្ញុំ ឡើងម៉ោភ្នំពេញ គិតទៅរហូត

ដានី : រហូតដល់ឆ្នាំ៩៦?

យ៉េង : បាទ!ដល់សមាហរណកម្មហើយ គេមានឡានមានអីបើកបានទេ ។

ដានី : បាទ!ចុះអ៊ំពេលដែលបែកយូរអ៊ំទៅលេងផ្ទះលើកដំបូងយ៉ាងម៉េចដែរ ស្ថានភាព ដូចថា ភូមិ ស្រុក អីខុសប្លែកពីមុនយ៉ាងម៉េច?

យ៉េង : កាលដែលខ្ញុំទៅហ្នឹងភូមិ ស្រុក មិនទាន់ខុសប្លែកប៉ុន្មានទេ ព្រោះកាលពេលនោះវានៅក្នុងលក្ខណៈគេហៅថាការដ្ឋាភិបាល កាលជំនាន់នោះព្រោះនៅស្រុកខ្ញុំគេកាប់សង្កត់ខ្លាំងដដែល ។

ដានី : បាទ!

យ៉េង : កូនសិស្សត្រូវខែស្រូវត្រូវ៥គីឡូ លក់ជូនរដ្ឋ អញ្ចឹងគឺថាអ្នកណាអត់ត្រូវទិញគេយកមកឲ្យរដ្ឋ អញ្ចឹងពេលនោះមិនទាន់ធូរធារនៅឡើយទេ

ដានី : អ៊ំនៅមើលស្គាល់ភូមិ ស្រុកអីដែរ?

យ៉េង : បាទ!មិនទាន់ខុសប្លែកអីទេ ប៉ុន្តែម៉ោរយៈក្រោយម៉ោបានតាំងពីដីធ្លី តាំងពីអីគេរកស៊ីចុះឡើង រកដូរញលក់ ដឹកពីខ្មែរទៅយួន ដឹកពីយួនម៉ោខ្មែរ ខ្លះក៏គេធ្វើស្រូវប្រាំងស្រូវអីទៅ ឥឡូវហ្នឹងគឺថាវារីកចំរើនមែនទែន ។

ដានី : បាទ!

យ៉េង : កាលដែលខ្ញុំទៅកាលពីមុនកន្លែងដូច ខាងព្រែកក្អោ កដែលខ្ញុំធ្លាប់នៅហ្នឹងកន្លែងដែលអត់មានផ្ទះនៅតែអត់មានផ្ទះដដែល ប៉ុន្តែប៉ុន្មានឆ្នាំក្រោយម៉ោឥឡូវនេះរកតែផ្លូវមើលដៃទន្លេសាបមើលមិនឃើញផង កាលពីមុនកន្លែងគីឡូលេខ៦ហ្នឹងវាមានប្រឡោះៗត្រង់កន្លែងរោងចក្រហ្នឹង ឥឡូវអត់មានទេ គេបាំងជិតទាំងអស់ ។

ដានី ៖ ចុះអ៊ំពេលដែលអ៊ំទៅស្រុកកំណើត ដូចជាបងប្អូន សាច់ញាតិជិតខាងអី ដូចថាកាលហ្នឹងយើងបែកគ្នាយូរទៅ យើងស្គាល់គ្នា?

យ៉េង ៖ ស្គាល់ខ្លះ មិនស្គាល់ខ្លះ សូម្បីតែប្អូនបង្កើតខ្ញុំមួយមកអោបកខ្ញុំ ហើយខ្ញុំសួរថាពីណាគេ ស្រែយំម៉ង់ ប្អូនស្រីខ្ញុំ ។

ដានី ៖ អ្ហូ!ដល់ពេលបែកយូរទៅ?

យ៉េង ៖ បាទ!វាប្លែកៗ ហើយបើបងៗអត់ទេ បងៗនៅស្គាល់ទាំងអស់

ដានី ៖ បាទ!ពេលឃើញហ្នឹងគាត់ចាស់ហើយ ពេលយើងបែកនោះ?

យ៉េង ៖ បាទ!ពេលយើងបែកនោះ មីមួយប្អូននៅជិតហ្នឹង ដល់ខ្ញុំទៅវាចង់ចាស់ជាងខ្ញុំទៀត ខ្ញុំហៅវាបង ជិះទូកដរទៅជួបគ្នា ។

ដានី ៖ ចាស់ជាងអ៊ំ?

យ៉េង ៖ បាទ!

ដានី ៖ អញ្ចឹងដល់ពេលនេះម៉េចដែរអ៊ំ បានជួបជុំបងប្អូនលើកទីមួយ?

យ៉េង ៖ អត់អីទេ ធម្មតា

ដានី ៖ ចុះអ៊ំ ដល់ពេលកាលហ្នឹងអ៊ំមានគ្រួសារមានអី ដូចថាកាលហ្នឹងអ៊ំមានផ្ទះសម្បែងដែរឬអត់កាលនៅស្រុកកំណើត?

យ៉េង ៖ បាទ!កាលហ្នឹងនៅបន្ទុកជាមួយម្ដាយមីង ព្រោះយាយខ្ញុំគាត់កំព្រា អត់ឪពុកម្ដាយ កេរ្តិ៍ពីដូនតាម៉ោផ្ទះហ្នឹង នៅផ្ទះជាមួយគ្នាហ្នឹង ។

ដានី ៖ ចុះអ៊ំមានកេរ្តិ៍ មានដីមានអីនៅស្រុកកំណើតទេ?

យ៉េង ៖ កេរ្តិ៍ អាកអីមាន ប៉ុន្តែដល់គេហៅថាបើនិយាយទៅបដិរូបចោលទាំងអស់ហើយ យើងអត់មានទាមទារអីទៀតទេ ។

ដានី ៖ អញ្ចឹងឥឡូវហ្នឹងអត់មានអីទៀតទេ?

យ៉េង ៖ អត់មានអីទេ ព្រោះឥឡូវគេចែកគ្នាអស់ហើយ

ដានី ៖ ឥឡូវនេះស្រុកកំណើតអ៊ំនៅនេះវិញហើយ?

យ៉េង ៖ បាទ!

ដានី ៖ ដីធ្លី កេរ្តិ៍ កូនចៅនៅនេះទាំងអស់?

យ៉េង ៖ បាទ!នៅនេះទាំងអស់

ដានី ៖ ដូចថាមនោសញ្ចេតនាអារម្មណ៍អី យើងដូចថានៅនោះវាលែងដូចជា?

យ៉េង ៖ ឥឡូវហ្នឹងខ្ញុំជំរាបលោកឲ្យត្រង់ ប្រសិនណាជាអ្នកនៅនេះ បើសិនជាអ្នកមមានលុយ ច្រើនហើយទៅរកស៊ីនោះគឺអាចរកស៊ីបាន គេថាទិញចូលលក់ចេញ

ដានី ៖ បាទ!

យ៉េង ៖ ហើយបើថាលុយបន្តិចបន្តួចទេទៅរកស៊ីមិនទាន់គេទេ ព្រោះដីធ្លីគ្មាន ដីធ្លីទៅវាសុទ្ធតែខាងអ៊ុក ញ៉ៅនេះ អ៊ុក ញ៉ៅនោះ អស់ហើយដី ។

ដានី ៖ បាទ!

យ៉េង ៖ ហើយនៅនេះវាគ្រាន់ ថារកស៊ីអីវានៅគ្រាន់ ប៉ុនគ្រាន់តែថា វាថ្លៃបេះ ថ្លៃត្រង់ថាឥឡូវកម្មករ បើថាយើងធ្វើច្រើនជួលគេថ្លៃកម្មករ ភ្ជួរដី គេភ្ជួរម៉ៅហិចតា៦រ៉ៃម៉ៅផាហ្នឹងគេភ្ជួរម៉ៅពាន់ យើងមាហិចតាវាត្រូវវា២ពាន់ដាង

ដានី ៖ ២ពាន់បាត់?

យ៉េង ៖ បាទ!ដាង២ពាន់បាត ភ្ជួរយកភ្ជួរថ្លៃដាងគេ ហើយដូចឥឡូវនេះសណ្តែកបេះ១គីឡូ ៥បាត

ដានី ៖ ជួល?

យ៉េង ៖ បាទ!ម៉ៅឈ្នួលបេះ អញ្ចឹងបានវាផាប់ ផាប់ត្រង់ថាកសិករធ្វើហ្នឹងវាអត់សូវចំណេញបើមានទឹកភ្លៀងជំនួយឲ្យម៉ោ គ្រាន់បើទៅគួរសម បើថាប៉ះពារចំកន្ទែងតាំស្ងួតផង ចប់បណ្តោយកសិករ គិតតែពូជពោតយើង១គីឡូ៩០ទៅ១គីឡូ១០០ដល់ពេលដែលយើងលក់បានតែ៤បាវកន្ទះទៅ៥បាវ តើសួរថាយ៉ាងម៉េចអាហ្នឹង ។

ដានី ៖ អញ្ចឹងឥឡូវហ្នឹងកសិករប្រជាជន យើងនៅនេះពិបាកដែរ ដោយសារបញ្ហាដូចថាធ្វើចំការអីដូចថាថ្លៃយើងទិញអីៗម៉ោថ្លៃ ហើយយើងលក់បានថោក ហើយពេលខ្លះដូចថាមេឃមិនអំណោយផលទៀតអត់សូវបានផលទេ ។

យ៉េង ៖ ហើយដូចឆ្នាំនេះ គឺថាកសិករហ្នឹងធ្លាក់ទឹកច្រើន ឥឡូវលោកឃើញស្រាប់ហើយ គ្រាន់ជន់លិចតាឡូងអស់ហ្នឹងរលួយអស់ហើយ សណ្តែកសៀងក្រហមអស់ហើយ អញ្ចឹងដូចថាវាពិបាកដែល ហើយអារឿងបញ្ហាដែលកសិផលប្រជាជនដែលធ្វើបានហើយ ហ្នឹងទីផ្សារមានលក់ ប៉ុន្តែវាមិនស្ថេរភាពរឿងតំលៃ កាលណាដែលយើងបានច្រើន ម៉ោបើគេឲ្យតែ៣បាតបើយើងមិនលក់ យើងទុកទៅៗទុកចោលហ្នឹង វាអត់មាន ។

ដានី ៖ ចុះមួយទៀតអ៊ំដូចថាអ៊ំរស់នៅហ្នឹងយូរហើយ ដូចថាអ៊ំមានញាតិមិត្ត អ៊ំមានដូចថាអ្នកជិតខាងញាតិមិត្តស្គាល់គ្នាអីច្រើន នៅហ្នឹងច្រើន ប៉ុន្តែនៅស្រុកកំណើតអ៊ំធ្លាប់នៅពី ក្មេងហើយមានសាច់ញាតិអីនៅនោះច្រើនដែរ ប៉ុន្តែនៅឆ្ងាយពីគ្នា ដូចថាអារម្មណ៍

មនោសញ្ចេតនាខុសគ្នាយ៉ាងម៉េចរវាងអ៊ំរស់នៅភូមិអ៊ំនៅនេះនៅម៉ាខ្សែនេះ ហើយនៅស្រុកកំណើតតាមមនោសញ្ចេតនាអ៊ំផ្ទាល់?

យ៉េង : ព្រោះ មនោសញ្ចេតនាវាមានដូចគ្នា គ្រាន់តែថាយូរៗទៅនឹកទៅ ដូចថាអានេះវាធ្លាប់នៅជាមួយអញ ធ្លាប់ដើរអីជាមួយគ្នា ធ្វើការងារ ហើយទៅជួបគ្នាក៏ធម្មតាដូចកាលយើងធ្លាប់ជួបគ្នាកាលពីដើមអញ្ចឹង ។

ដានី : បាទ!ហើយចុះនៅនេះវិញ?

យ៉េង : នៅនេះក៏ត្បិតតែយើងធ្លាប់ស្គាល់គ្នា មិនជាប់ខ្សែលោហិត ព្រោះអានេះចំរុះ គេហៅថាចំរុះ បើនិយាយទៅ តាកែវ កំពត ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ សៀមរាបអីនៅជុំគ្នាទាំងអស់ អញ្ចឹងដូចតែបងប្អូនដូចតែយើងនៅស្រុកហ្នឹងដែរ ដល់អ្នកណាមានធុរៈអីឈឺឆ្កាត់អីយើងជួយគ្នាទៅ ហើយរវល់បុណ្យទានយើងប្រាប់គ្នាទៅ ។

ដានី : បាទៗ!ជួយគ្នាទៅ?

យ៉េង : បាទ!ជួយគ្នាទៅ វាជាធម្មតា

ដានី : ចុះពេលដែលអ៊ំទៅលេងស្រុកកំណើត អ៊ំទៅបានយូរដែរឬអត់?

យ៉េង : បាទ!ជួនកាលមួយអាទិត្យ ជួនកាលកន្លះខែ

ដានី : ដល់ពេលអ៊ំទៅម្តងមួយអាទិត្យ ម្តងកន្លះខែហ្នឹង ពេលអ៊ំទៅនោះមាននឹកនៅនេះដែរឬអត់?

យ៉េង : បាទ!អាហ្នឹងគឺថាវាត្រូវការត្រូវនឹកទាំងអស់ ឥឡូវយើងថាយើងទៅព្រោះកន្លែងនេះបើនិយាយពីប្រកបការងារវិញគឺថា វាត្រូវជាប្រចាំ កាលណាទៅយូរពេកក្រែងលោភ្លៀង ដល់ខែដាំដុះហើយ គេដាំយើងទៅនៅនោះ វានឹកឃើញអារឿងបញ្ហាហ្នឹងហើយអញ្ចឹងដល់ខែដាំដុះហើយ ហើយគឺថាការដាំដុះអីខ្លាចវាមិនទាន់គេ ។

ដានី : អ៊ំខស្សាហ៍ទៅស្រុកដែរអញ្ចឹង?

យ៉េង : ១ឆ្នាំទៅម្តង ឆ្នាំនេះខ្ញុំទៅ ឆ្នាំទៅមិញខ្ញុំអត់បានទៅ

ដានី : អញ្ចឹង១ឆ្នាំទៅម្តង ទៅញឹកដែរ?

យ៉េង : បាទ!ហើយយើងគិតថាដូចឥឡូវហ្នឹងឡានពីនេះទៅស្វាយគិតទៅ៤ម៉ឺន ។

ដានី : ៤ម៉ឺនថ្លៃម៉េះ ពីនេះទៅជិតដែរ

យ៉េង : ចុះឥឡូវលោកមើលផ្លូវមើល អាហ្នឹងវាអញ្ចឹង បើយើងមិនជិះដើរទៅ

ដានី : ប៉ុន្តែបើតាមធម្មតា?

យ៉េង ៖ ធម្មតាខាងក្រៅ -៧០៨០ ក្នុងកាបីន១០០

ដានី ៖ អូរខុសគ្នាច្រើនដែរ?

យ៉េង ៖ ហើយសព្វថ្ងៃនេះ៨០០ទៅ៩០០នោះ។

ដានី ៖ បាទៗ!

យ៉េង ៖ ហើយបើសិនណាទៅចំថ្ងៃខែភ្ជុំ ឬក៏ចូលឆ្នាំ អញ្ចឹងបានថាឥឡូវវាធ្លល់ ឡានហ្នឹងបើទៅស្រុកគេបើថាពេលហ្នឹងគឺថា គេត្រូវប្រថយថ្លៃ ប៉ុនបើស្រុកយើងពេលហ្នឹងគឺថ្លៃកាត់ខ្លាំងម៉ង

ដានី ៖ ដោយសារមនុស្សទៅច្រើន?

យ៉េង ៖ បាទ!គិតពេលដែលខ្ញុំទៅ២៥០ ទៅមុនចូលឆ្នាំ២៥០ ដល់ចូលឆ្នាំហើយវិលត្រលប់មកវិញ៣០០អញ្ចឹងបានថា។

ដានី ៖ ដូចថាអ្នករត់ឡានគាត់ឆ្លៀតឱកាសពេលហ្នឹង ពេលមានមនុស្សច្រើន

យ៉េង ៖ អាហ្នឹងមែនអ្នករត់ឡានទេ អាហ្នឹងម៉ោពីក្រុមហ៊ុនថៅកែនោះម៉ង អ្នករត់គ្នាដឹងអីគ្នាសំបុត្រគេអ្នកលក់នោះ គ្នាដឹងតែបើក

ដានី ៖ អញ្ជើញទៅជិះឡានក្រុងយ៉ាងម៉េច?

យ៉េង ៖ ឡានក្រុង ទៅឡានក្រុងម៉ោឡានក្រុង

ដានី ៖ អ៊ូរអញ្ចឹង!

យ៉េង ៖ ប៉ុបអាហ្នឹងឥឡូវទំលាក់ទៅលើអ្នកណា ទលាក់ទៅពួកអាឈ្មួញនោះ ឬទំលាក់ទៅលើអ្នកណា

ដានី ៖ អាហ្នឹងវាទៅតាមទាំងអស់គ្នា ទាំងរដ្ឋាភិបាលអ្នកគ្រប់គ្រងអញ្ចឹងណាស់!

យ៉េង ៖ បាទ!

ដានី ៖ យើងត្រូវមើលដែរ ព្រោះថាប្រជាពលរដ្ឋគាត់ត្រូវធ្វើដំណើរពេលបុណ្យទានហ្នឹងគួរតែសម្រួលធ្វើ

យ៉េង ៖ ប៉ុន្តែដល់យើងនិយាយអញ្ចឹង អាហ្នឹងដូចថាពួកឈ្មួញវាឆ្លៀតឱកាសបានតែ ភ្ជុំ ចូលឆ្នាំប៉ុន្មានថ្ងៃហ្នឹង ហើយប៉ុន្មានថ្ងៃហ្នឹងមិនតិចទេលោក បើគិត

ដានី ៖ បាទ!

យ៉េង ៖ ហើយមនុស្សឲ្យពេញៗឡាន

ដានី ៖ បាទ!អញ្ចឹងខ្ញុំដូចជាអស់សំនួរអីត្រូវសួរអ៊ំទៀតហើយ ព្រោះចំណាយពេលយូរដែរ ប្រហែលជាជិត២ម៉ោងហើយ បាទចុះអ៊ំមានអ៊ីចង់បន្ថែមនូវអារអ៊ីដែលខ្ញុំអត់បានសួរនាំអ៊ំទៀតទេ?

យ៉េង ៖ ខ្ញុំអត់មានអីទេ ប៉ុនថាបើសិនណាជាថាលោកបានអញ្ជើញមកដល់ហើយ ដឹងព្រឹត្តិការណ៍នៅកន្លែងនេះ ដើម្បីជួយធ្វើម៉េចឲ្យវា គេហៅថាស្តេរភាពអារឿងរបស់ របរដែលកសិករធ្វើបានហើយហ្នឹងឲ្យវាមាន គេថាឈ្មួញចេញហ្នឹងទាក់ទងឲ្យបានតំលៃថ្លៃថ្នូរហ្នឹងឲ្យវាស្តេរភាព បើថា៥០០ឲ្យវាពិតជា៥០០ហ្នឹងម៉ង ថ្ងៃនេះ៥០០ ថ្ងៃនោះ៤០០ ។

ដានី ៖ បាទ!ពួកខ្ញុំជាអ្នកយកពត៏មាន ខ្ញុំសរសេរជារឿងរ៉ាវដូចថាជីវិតផ្ទាល់ខ្លួន ដូចជាអ៊ំមានប្រសាសន៍ប្រាប់ខ្ញុំអញ្ចឹង ខ្ញុំសរសេរទៅ ហើយគេមើលឃើញ ដូចខាងរដ្ឋាភិបាលគេមើលឃើញគេអាចអនុវត្ត គេចាត់វិធានការម៉េចខាងគេ ខ្ញុំគ្រាន់តែអ្នកយកពត៏មាន

យ៉េង ៖ អាហ្នឹងអញ្ចឹងហើយ ដឹងថាអ្នកយកពត៏មានហើយ ប៉ុនគ្រាន់តែថាអ្នកនេះធ្វើម៉េចដើម្បីជួយផ្សព្វផ្សាយ ដើម្បីឲ្យយើងយល់អាពីបញ្ហាហ្នឹង ។

ដានី ៖ ហើយសំនួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់ដឹងពីយោបល់របស់អ៊ំ ដូចថាឥឡូវនៅខាងភ្នំពេញនោះគេមានតុលាការ គេបង្កើតតុលាការគេកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមក្នុងហ្នឹងមាន នួន ជា លោក អៀង សារី ប្រពន្ធរបស់គាត់ អ៊ំ ខៀវ សំផន អញ្ចឹងហើយកាលមុនគេកាត់ទោសតាឌុច តាឌុចគេកាត់ទោសហើយៗ បើតាមចិត្តអ៊ំវិញអ៊ំយល់ឃើញយ៉ាងម៉េចដែរ ចំពោះតុលារការដែលគេកំពុងតែកាត់ទោសរាល់ថ្ងៃនេះ?

យ៉េង ៖ បាទ!អារឿងបញ្ហាតុលាការកាត់ទោសនេះ ខ្ញុំថាបើខ្ញុំពិនិត្យពិចារណាមើលទៅគឺថាបើនិយាយទៅតាម ផ្លូវព្រះពុទ្ធសាសនាវិញគឺថា បើយើងមិនចងពារគ្នីរួច បើយើងចងពារតទៅទៀតគឺថា ចុះបើមនុស្សស្លាប់ទៅហើយ យកមនុស្សរស់គាត់ទៅទៀតទៅ តើវាចំណេញប្ញខាត ខ្ញុំគ្រាន់តែយល់ថាប៉ុណ្ណឹងទេ ។

ដានី ៖ នេះជាការយល់របស់អ៊ំ?

យ៉េង ៖ បាទ!ប៉ុន្តែអ្នកខ្លះគេថា ម៉ោអ្នកណាឹងបានជាអ្នកនៅក្នុងគ្រួសារគេបាត់បង់ គ្រួសារគេត្រូវស្លាប់អី ក៏ប៉ុន្តែនេះសង្គមបត់បែន ខ្ញុំគិតថាសង្គមបត់បែនវាអញ្ចឹង ឥឡូវយើងគិតថាកាលអង្គរ ដែលក៏សាងអង្គរ តើមនុស្សស្លាប់អស់ប៉ុន្មាននាក់ ។

ដានី ៖ បាទៗ!ត្រូវអ៊ំ កាលជិនាន់ហ្នឹងក៏សាងអង្គរស្លាប់អស់ច្រើន ។

យ៉េង ៖ បាទ!

ដានី ៖ ប៉ុន្តែមួយនេះដោយសារសង្គមយើងវាវិវត្តន៍ពីមួយជំនាន់ទៅមួយជំនាន់

យ៉េង ៖ បាទៗ!

ដានី ៖ ហើយក្រោយម៉ោវាមានទាក់ទងនឹងច្បាប់អន្តរជាតិ ទាក់ទងគ្នាទៅវិញទៅម៉ោមានជំនួយមានជំនួយគ្នាទៅវិញទៅម៉ោ ក្រោយម៉ោវាមានច្បាប់បង្កើតឡើងច្រើនអញ្ចឹង ហើយតុលាការនេះកើតឡើងដោយសារ មានការចូលរួមពីអង្គការសហប្រជាជាតិ ហើយនឹងរដ្ឋាភិបាលយើងសព្វថ្ងៃហ្នឹង គេបង្កើតហ្នឹងជំនួយមកពីប្រទេសខាងក្រៅម៉ោ គេបង្កើតម៉ោដើម្បីទុកជាប្រវត្តិសាស្ត្រសម្រាប់ក្មេងៗជំនាន់ក្រោយដែរ ដូចថាយើងមានតុលា ការដូចថាកាលពីសម័យ៣ឆ្នាំ ពួកអាំតាៗហ្នឹងគាត់ជាអ្នកគ្រប់គ្រង វាធ្វើឲ្យមានមនុស្សស្លាប់ច្រើនដូចថា អ្នកខ្លះគេថាជាង៣លាន អ្នកគេថាជាង២លាន អញ្ចឹងវាមិនដឹងថាចំនួនណាវាពិតប្រាកដ ប៉ុន្តែតុលាការនេះគេបង្កើតឡើងគ្រាន់តែថាចង់ឲ្យពួកគាត់ជាអ្នកដឹកនាំហ្នឹងទទួលខុសត្រូវពីអាអ៊ីដែលបាត់បង់ទៅអញ្ចឹង ជាប្រវត្តិសាស្ត្រ បើតាមគិតទៅពួកគាត់ចាស់ៗអស់ហើយ អាយុគាត់៨០ជាង យើងកាត់ទោសគាត់យ៉ាងម៉េចយើងមិនអាច

យ៉េង ៖ នៅតែថ្ងៃស្លាប់

ដានី ៖ គាត់មិនដឹងជារស់បានប៉ុន្មានឆ្នាំទៀតទេ

យ៉េង ៖ បាទ!ហើយចុះសម្រាប់យកកម្មអីទៀតៗ ហើយឥឡូវយើងគិតទៅប្រទេសកម្ពុជា វាមានការក្រឡាប់ចាក់ប្រែប្រួលការកាប់សម្លាប់ ចុះប្រទេសលើសកលលោកហ្នឹងមានដែរឬអត់? ឬមានតែប្រទេសកម្ពុជាមួយទេ?

ដានី ៖ អូ!មានច្រើនដែរអ៊ំ ដូចថានៅខាងអឺរ៉ុបកាលពីជំនាន់សង្គ្រាមលោកលើកទី២ មានប្រទេសអាឡឺម៉ង់ របបអ៊ីក្លែ យើងហៅអ៊ីក្លែៗហ្នឹង ។

យ៉េង ៖ បាទៗ!

ដានី ៖ អ៊ីក្លែហ្នឹងគាត់សម្រាប់ជនជាតិសូហ៊្វីសហ្នឹងអស់ច្រើនដែរ ដូចថាពេលគាត់ធ្វើការឈ្លានពានប្រទេសនៅអឺរ៉ុប ហើយនឹងជនជាតិសូហ៊្វីសហ្នឹងនៅប្រទេសអាឡឺម៉ង់ ហើយនៅកន្លែងផ្សេងៗទៀតគាត់ចាប់យកទៅដាក់ក្នុងរោងចក្រអញ្ចឹងទៅ បើកគាសឲ្យថប់ដង្ហើមស្លាប់អស់ច្រើន ហើយពួកអ៊ីក្លែហ្នឹងក៏គេកាត់ទោសអ្នកដឹកនាំដូចតែពួកយោធា ព្រោះអ៊ីក្លែគេស្លាប់នៅក្នុងពេលសង្គ្រាមហើយគេកាត់ទោស ហើយនៅប្រទេសអាហ្វ៊ិក ដូច

ជានៅខាងវូវ៉ាន់ដា នៅខាងសារ៉ាលីអូនហ្នឹងគេហ្នឹងគេមានកាត់ទោសមេដឹកនាំដែរ ពីព្រោះគាត់ទោសពីការដែលគាត់ទទួលខុសត្រូវ នៅក្នុងរបបរបស់គាត់ដែលធ្វើឲ្យមានប្រជាជន មានអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់គាត់ហ្នឹងស្លាប់ច្រើន តែគាត់មិនមែនគាត់បានទៅសម្លាប់ដោយផ្ទាល់ដៃទេ គ្រាន់តែគាត់មានទោស ដោយសារគាត់ជាអ្នកដឹកនាំ ជាអ្នកគ្រប់គ្រងគាត់អត់បានចាត់វិធានការពេលហ្នឹង ដូចថាមានការស្លាប់អញ្ចឹងទៅ អ្នកគ្រប់គ្រងត្រូវតែទទួលខុសត្រូវ ពីព្រោះប្រសិនបើមានអញ្ចឹងគាត់គ្រប់ គ្រងគាត់ត្រូវចាត់វិធានការទប់ស្កាត់កុំឲ្យមានការស្លាប់អីអញ្ចឹង អញ្ចឹងមានតែប្រទេស ផ្សេងៗអញ្ចឹងដូចថាយើងរស់នៅជាមួយគេ មានឆ្លងកាត់តាមប្រវត្តិសាស្រ្តអញ្ចឹងយើងដូចថាគោរពតាមច្បាប់អន្តរជាតិយើងធ្វើអីដូចគេអញ្ចឹង អានេះបើតាមខ្ញុំយល់ដឹងខ្ញុំរៀនសូត្រម៉ោ ។

យ៉េង : បាទ!អាហ្នឹងវាអញ្ចឹងហើយ អញ្ចឹងបានថាយើងបើនិយាយពីកាត់ទោសទឹមឃើញដែលភ្ញាក់ផ្អើលខ្លាំងគឺកម្ពុជាហ្នឹងម៉ង ដែលភ្ញាក់ផ្អើលលើសកលលោកខ្លាំង ។

ដានី : បាទៗ!នៅកម្ពុជានេះជាលើកទី១ហើយ ដែលយើងមានតុលាការអន្តរជាតិ រួមជាមួយខ្មែរយើង ហើយកាត់ទោសពួកគាត់ជាលើកទី១ ដែលជាមេដឹកនាំប្រវត្តិសាស្រ្តដែលជាមេដឹកនាំខ្មែរយើងដែលត្រូវបានគេ កាត់ទោសអីអញ្ចឹង បាទ!អញ្ចឹងខ្ញុំដូចជាអស់ហើយ អ៊ុំមានអីចង់បន្ថែមទៀត?

យ៉េង : បាទ!ខ្ញុំអត់មានអីចង់បន្ថែមទេ ខ្ញុំគ្រាន់តែសុំតែប៉ុណ្ណឹងទេ សុំធ្វើម៉េចឲ្យបានលោកជួយផ្សព្វផ្សាយទៅ ដើម្បីឲ្យកសិកររបស់ប្រជាជនធ្វើបានហើយ ឲ្យវាមានតំលៃថ្លៃថ្នូរ ឲ្យវាសមល្មម ព្រោះធ្វើចំណាយថវិការច្រើន ដល់បានលក់ទៅវិញបានថវិកាចូលតិច ។

ដានី : បាទៗ!អញ្ចឹងខ្ញុំអរគុណអ៊ុំច្រើន ដែលចំណាយពេលឲ្យខ្ញុំសួរនាំទាក់ទងរឿងពីជីវិតផ្ទាល់ខ្លួនរបស់អ៊ុំ ពីរឿងរ៉ាវប្រវត្តនៅម៉ាឡៃយើងនេះអ៊ុំ ។

យ៉េង : បាទ!

«ចប់»